# មាតិកា

## I-ខុទ្ទកាល័យព្រះមហាក្សត្រ

### ១-ព្រះរាជក្រម

៣០-៨-២០០៦ -ព្រះរាជក្រម នស/រកម/០៨០៦/០២៤ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ៦២៦៩

### ២-ព្រះរាជក្រឹត្យ

២៩-៨-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/០៨០៦/៣៦៥ ស្តីពីសញ្ញាស័ក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌ អភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ៦២៧២

## II-រាជរដ្ឋាភិបាល

### អនុក្រឹត្យ

០១-៩-២០០៦ -អនុក្រឹត្យលេខ ៩០ អនក្រ.បក ស្តីពីការបង្កើត ការិយាល័យអនុព័ន្ធយោធា ៦២៨៨

០៤-៩-២០០៦ -អនុក្រឹត្យលេខ ៩១ អនក្រ.បក ស្តីពីការប្រែក្លាយវិទ្យាស្ថានជាតិសុខភាពសាធារណៈ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ៦២៨៩

៣១-៨-២០០៦ -អនុក្រឹត្យលេខ ៦១០ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៣០១

០១-៩-២០០៦ -អនុក្រឹត្យលេខ ៦១១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៣០២

០១-៩-២០០៦ -អនុក្រឹត្យលេខ ៦១២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ៦៣០៣

០១-៩-២០០៦ -អនុក្រឹត្យលេខ ៦១៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៣០៤

០១-៩-២០០៦ -អនុក្រឹត្យលេខ ៦១៤ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៣០៦

០១-៩-២០០៦ -អនុក្រឹត្យលេខ ៦១៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៣០៨

០៤-៩-២០០៦ -អនុក្រឹត្យលេខ ៦១៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ៦៣០៩

០៤-៩-២០០៦ -អនុក្រឹត្យលេខ ៦១៧ អនក្រ.តត ស្តីពីការទទួលស្គាល់គណៈកម្មាធិការកណ្តាល អាណត្តិទី ៤ សមាជិកបំរុង ឥស្សរជន និងអគ្គលេខាធិការ អគ្គលេខាធិការរង កាកបាទក្រហមកម្ពុជា ៦៣១០

០៤-៩-២០០៦ -អនុក្រឹត្យលេខ ៦១៨ អនក្រ.តត ស្តីពីការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងនាយនគរបាលជាតិ ៦៣១៣

# III.ការងារបណ្តាក្រសួង

## ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៤-៩-២០០៦ -ប្រកាសលេខ ១៧៦ MOC/SM 2006 ស្តីពីវិធានការចាំបាច់មួយចំនួនសំរាប់គ្រប់គ្រងការនាំចេញ ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ៦៣១៤

១០-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧២៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **រាជធីតា គ្រុប អ៊ីុន (អ ធី ឌី)** ៦៣១៦

១០-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧២៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **អាន់លីមីធីត អិកសេស** ៦៣១៨

១០-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧២៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ច្រាផាត់សន** ៦៣២០

១០-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៣០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាយ អូច ខេមបូ** ៦៣២២

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៣៧ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហាយ យ៉ាង អ៊ីមផត អិចផត** ៦៣២៤

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៤០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ហ្សាលីន គ្រុប ខូ អិលធីឌី** ៦៣២៦

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៤១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ជេនេរ៉ល ប្រ៊ីហ្វេសិនណល ស៊ីឃ្យួរីធី សឺវីស (ជី ភី អេស)** ៦៣២៨

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៤៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទី.ខេ គ្លូបិល ត្រេឌីង** ៦៣៣០

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៤៨ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **(ខេមបូឌា) យុនណាន អ៊ិនដាសស្ទ្រី** ៦៣៣២

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៥១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ទេង ស្រ៊ុន ហួត ត្រេឌីង** ៦៣៣៤

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៥២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប៊ី អេស ស៊ី អ៊ីមផត អិចផត** ៦៣៣៦

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៥៤ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ឡាវ ហាំង ហេង គ្រុប** ៦៣៣៨

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៥៦ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ភី អ៊ី ខ្មែរកង់រ ភីធីអ៊ី អិលធីឌី** ៦៣៤០

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៥៩ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូរ៉ូអាស៊ី ផ្លែនថេសិន** ៦៣៤២

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៦០ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **យូរ៉ូ អេឡិកទ្រិខល** ៦៣៤៤

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៦១ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **សំ វូ អេឡិចទ្រិក** ៦៣៤៦

១១-៧-២០០៦ -លិខិតបញ្ជាក់លេខ ១៧៦២ ពណ.នតក ស្តីពីការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់របស់ក្រុមហ៊ុន **ប្រ្លាន ថៅអឺរ** ៦៣៤៨

# ព្រះរាជក្រម

នស/រកម/០៩០៦/០២៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មមាត្រា១៨នៃច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញរបស់រដ្ឋសភា នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ០៩ ខែសីហា ឆ្នាំ ២០០៦ នាសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី២ ហើយត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៨១/០០៨/២០០៦ កបធ.ច ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៦ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

# ច្បាប់
# ស្តីពី
# វិសោធនកម្មមាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្ម
# នៃព្រះរាជាណាចក្រកម្ពុជា

**មាត្រាមួយ.-**

មាត្រា ១៨ នៃច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ត្រូវបានកែប្រែដូចខាងក្រោម :

**មាត្រា ១៨ .- ថ្មី**

អគ្គសវនករ និងអគ្គសវនកររង ត្រូវបានតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់រាជរដ្ឋាភិបាល និងដោយមានការបោះឆ្នោតទុកចិត្តពីរដ្ឋសភាតាមសំឡេងគាំទ្រភាគច្រើនដាច់ខាតនៃចំនួនសមាជិករដ្ឋសភាទាំងមូល ។

អគ្គសវនករ និងអគ្គសវនកររង នឹងត្រូវបានទទួលការតែងតាំងសម្រាប់អាណត្តិ ៥ (ប្រាំ) ឆ្នាំ ហើយអាចទទួលការតែងតាំងតែមួយដងទៀតប៉ុណ្ណោះ នៅពេលចប់អាណត្តិទី ១ របស់ខ្លួន ។

ក្នុងករណីដែលអគ្គសវនករ ឬ អគ្គសវនកររងទទួលអនិច្ចកម្ម ឬ លាលែង ឬ បាត់បង់សមត្ថភាពពលកម្ម ឬ មានកំហុសជាទម្ងន់នោះ ត្រូវជ្រើសតាំងអគ្គសវនករ ឬ អគ្គសវ-

នកររងថ្មីជំនួស តាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់នេះ ។

អគ្គសវនករមានឋានៈនិងបុព្វសិទ្ធិស្មើនឹងទេសរដ្ឋមន្ត្រី និងអគ្គសវនកររងមានឋានៈនិងបុព្វសិទ្ធិស្មើនឹងរដ្ឋមន្ត្រី ។

**មាត្រា ពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ៣០ ខែសីហា ឆ្នាំ ២០០៦

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

នស/រកម.០៨០៦.០៣៩

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

លេខ: ៣៥៧ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ស៊ុំ ចិនកេន**

# ព្រះរាជក្រឹត្យ

នស/រកត/០៨០៦/៣៦៥

## ស្តីពី

## សញ្ញាសក្តិ និងឯកសណ្ឋានមន្ត្រីក្របខ័ណ្ឌអភិបាល និងក្របខ័ណ្ឌឧបការី នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រត្នខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០២០៣/០០៧ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមន្ត្រីរាជការនៃក្រុមនីតិប្បញ្ញត្តិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៤/២២១ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងប្រធានក្រុមប្រឹក្សាធម្មនុញ្ញសម្រាប់អាណត្តិ ៣ឆ្នាំ លើកទី៣
- តាមសេចក្តីក្រាបបង្គំទូលស្នើសុំរបស់ឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

# ត្រាស់បង្គាប់

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ត្រូវបានបង្កើតសញ្ញាសក្តិ និង ឯកសណ្ឋាន សម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ២.-**

សញ្ញាសក្តិមាន សក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវទាំងសងខាង និង សក្តិកន្ទាស់ ។

ឯកសណ្ឋានមានឯកសណ្ឋានផ្លូវការ និង ឯកសណ្ឋានប្រពៃណីជាតិ ។

សញ្ញាសក្តិ និង ឯកសណ្ឋាននេះ ប្រើប្រាស់នៅពេលចូលរួមពិធីបុណ្យប្រពៃណីជាតិ ពិធីបុណ្យជាតិ ពិធីផ្លូវការផ្សេងៗ ។

**មាត្រា ៣.-**

ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់និមិត្តសញ្ញារបស់ក្រុមប្រឹក្សាធម្មនុញ្ញ សម្រាប់ដាក់នៅលើសក្តិចុងកអាវ សក្តិស្មានិង នៅលើសក្តិកន្ទាស់សម្រាប់ក្ខាស់លើអាវបុរស ឬ នារី ឬ លើក្រមាពានារបស់នារីនៃមន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ២

## អំពីសញ្ញាសក្តិ

**មាត្រា ៤.-**

សញ្ញាសក្តិនៃមន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ត្រូវបានកំណត់ដូចតទៅ ÷

**១ . ក្របខ័ណ្ឌមន្ត្រីអភិបាល**

**ក . សក្តិចុងកអាវ**

សក្តិចុងកអាវមានផ្ទៃកម្ទីពណ៌ខៀវចាស់ រចនាតុបតែងដោយនៅផ្នែកខាងដើម និង ខាងក្រោមតួសក្តិ មាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញពណ៌មាស ។ នៅផ្នែកកណ្តាលរហូតដល់ចុងនៃតួសក្តិមានក្បាច់ភ្ញីទេសពណ៌មាស រចនាជាសន្ទឹក ផ្លែនិងផ្កាដែលតំណាងនូវដំណាំរួមផ្សំនៅកម្ពុជា ហើយមានក្បាច់គ្របកឈូកពណ៌មាស ហ៊ុំព័ទ្ធក្បាច់ភ្ញីទេស និងនិមិត្តសញ្ញា ពីផ្នែកខាងលើ និង ផ្នែកចំហៀងខាងមុខ ។ នៅជាយនៃតួសក្តិចុងកអាវ មានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាស ជាពីរជ្រុង គឺជ្រុងខាងដើម និង ជ្រុងខាងលើ ចំនួន ០៣ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិឧត្តមអភិបាល ចំនួន០២ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន០១ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិអភិបាល ។ នៅបាតក្រោមបង្អស់ និង ផ្នែកខាងចុងនៃសញ្ញាសក្តិចុងកអាវ មានក្បាច់ពួរវេញមួយខ្សែពណ៌មាស ។

**ខ្នាតសក្តិចុងកអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷**

-មានរាងជាប្រលេឡូក្រាម

-បណ្តោយ ប្រវែង ០៩.០០ សង់ទីម៉ែត្រ

-ទទឹង ប្រវែង ០៣.៥០ សង់ទីម៉ែត្រ

**ខ . សក្តិស្មា**

សក្តិស្មាមានផ្ទៃកម្ទីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាសចំកណ្តាល ដែលរចនាជាសន្ទឹក ផ្លែ និង ផ្កា តំណាងនូវដំណាំរួមផ្សំនៅកម្ពុជា ។ នៅពីខាងលើក្បាច់ភ្ញីទេស មាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញពណ៌មាស ហើយនៅលើនិមិត្តសញ្ញានេះ មានឡេវរូបព្រះសង្ហារពណ៌មាសមួយ ដែលមានអង្កត់ផ្ចិតប្រវែង ០១.៨០ សង់-ទីម៉ែត្រ ។ ឡេវ និមិត្តសញ្ញា និង ក្បាច់ភ្ញីទេសហ៊ុំព័ទ្ធជុំវិញដោយក្បាច់ត្របកឈូកពណ៌មាស ។ នៅជាយនៃតួសក្តិស្មាមានក្បាច់ជរជាយរចនាជាខ្សែពួរវេញពណ៌មាស ចំនួន ០៣ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិឧត្តមអភិបាល ចំនួន ០២ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន ០១ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិអភិបាល ។

**ខ្នាតសក្តិស្មា ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷**

-បាតក្រោម ប្រវែង ០៦.០០ សង់ទីម៉ែត្រ

-ទទឹងមុខកាត់ផ្នែកខាងលើ ប្រវែង ០៤.៥០ សង់ទីម៉ែត្រ មានរាងកោងជាមុំទាល

-បណ្តោយពីលើដល់បាតក្រោម ប្រវែង ១២.០០ សង់ទីម៉ែត្រ

**គ . សក្តិចុងដៃអាវ**

សក្តិចុងដៃអាវមានផ្ទៃកម្ទីពណ៌ខៀវចាស់ រចនាតុបតែងដោយក្បាច់ភ្ញីទេសពណ៌មាស ដែលរចនាជាសន្ទឹក ផ្លែ និង ផ្កា តំណាងនូវដំណាំរួមផ្សំនៅកម្ពុជា ហើយមានក្បាច់ត្របកឈូកពណ៌មាស ហ៊ុំព័ទ្ធក្បាច់ភ្ញីទេស នៅជាយផ្នែកខាងលើ និង ផ្នែកចំហៀងទាំងសងខាង ។ នៅជាយនៃតួសក្តិចុងដៃអាវមានក្បាច់ជរជាយ រចនាជាខ្សែពួរវេញពណ៌មាស ហ៊ុំព័ទ្ធជាបីជ្រុង គឺនៅផ្នែកខាងលើ និង ផ្នែកចំហៀងទាំងសងខាង ចំនួន ០៣ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិឧត្តមអភិបាល ចំនួន០២ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិវរអភិបាល និង ចំនួន ០១ ខ្សែសម្រាប់សម្គាល់ឋានន្តរសក្តិអភិបាល ។ នៅបាតក្រោមបង្អស់នៃសញ្ញាសក្តិចុងដៃអាវ មានក្បាច់ពួរវេញមួយខ្សែពណ៌មាស ។

**ខ្នាតសក្តិចុងដៃអាវ ត្រូវបានកំណត់ដូចខាងក្រោមនេះ ÷**

-មានរាងជាបួនជ្រុងទ្រវែង

-បណ្តោយ ប្រវែង ៣២.០០ សង់ទីម៉ែត្រ

-ទទឹង ប្រវែង ០៨.០០ សង់ទីម៉ែត្រ

**រូបគំនូរសក្តិចុងកអាវ សក្តិស្មា និង សក្តិចុងដៃអាវទាំងសងខាង សម្រាប់មន្ត្រី ÷**

-ឋានន្តរសក្តិឧត្តមអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ១

-ឋានន្តរសក្តិវរអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ២

-ឋានន្តរសក្តិអភិបាល មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យនេះ ។

**ឃ . សក្តិកន្ធាស់**

សក្តិកន្ធាស់សម្រាប់ក្ធាស់លើអាវបុរស នារី ឬ លើក្រមាពាក់នារី សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល មានរាងពងក្រពើ កម្ពស់ ០៦,០០ សង់ទីម៉ែត្រ ទទឹង ០៥,០០ សង់ទីម៉ែត្រ ។

នៅផ្ទៃកណ្តាលខាងក្នុងនៃសក្តិកន្ធាស់មានផ្ទៃពណ៌ក្រហម និង មាននិមិត្តសញ្ញាក្រុមប្រឹក្សាធម្មនុញ្ញពណ៌មាស។ នៅផ្ទៃខាងក្រៅមានផ្ទៃពណ៌ខៀវព័ទ្ធពីខាងក្រៅរង្វង់និមិត្តសញ្ញា ដែលហៅថា " ហាមមណ្ឌល " ។ នៅផ្នែកខាងលើនៃហាមមណ្ឌលមានចារឹកអក្សរខ្មែរថា " **ព្រះរាជាណាចក្រកម្ពុជា** " ជាពណ៌មាស និង នៅផ្នែកខាងក្រោមមានចារឹកអក្សរខ្មែរថា" **អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ**" ជាពណ៌មាស ។ នៅចន្លោះអក្សរខ្មែរទាំងពីរនេះ មានក្បាច់ដកចន្ទទ័ពណ៌មាស ស្ថិតនៅសងខាងនៃហាមមណ្ឌល ។ នៅជាយខាងក្រៅនៃហាមមណ្ឌលហ៊ុំព័ទ្ធដោយក្បាច់ត្របកឈូក និង មានក្បាច់ចំណងមួយ ដែលរចនាដោយក្បាច់ភ្ញីទេសពណ៌មាស មានស្លឹកម្ខាង១ចំនួន ០៤ និងផ្លែ ម្ខាង១ចំនួន ០៣ ព័ទ្ធជុំវិញក្បាច់ត្របកឈូក ។

**២ . ក្របខ័ណ្ឌមន្ត្រីឧបការី**

សញ្ញាសក្តិ ( សក្តិចុងកអាវ សក្តិស្មា សក្តិចុងដៃអាវទាំងសងខាង និង សក្តិកន្ធាស់ ) សម្រាប់មន្ត្រីក្របខ័ណ្ឌឧបការី មានសណ្ឋាន រូបភាព និង មានការបែងចែកទៅតាមឋានន្តរសក្តិ ដូចសញ្ញាសក្តិមន្ត្រីក្របខ័ណ្ឌអភិបាលដែរ ប៉ុន្តែខុសគ្នាត្រង់សញ្ញាសក្តិសម្រាប់មន្ត្រីក្របខ័ណ្ឌឧបការី គឺពណ៌ប្រាក់។

**រូបគំនូរសក្តិចុងកអាវ សក្តិស្មា និង សក្តិចុងដៃអាវទាំងសងខាង សម្រាប់មន្ត្រី ÷**

-ឋានន្តរសក្តិនាយឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៤

-ឋានន្តរសក្តិឧបការីដើមខ្សែ មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៥

-ឋានន្តរសក្តិឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៦នៃព្រះរាជក្រឹត្យនេះ ។

**រូបគំនូរសក្តិកន្ធាស់សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យនេះ ។**

**៣ . សញ្ញាសក្តិសម្រាប់មន្ត្រីរាជការជានារី**

សក្តិចុងកអាវ សក្តិស្មា និង សក្តិចុងដៃអាវ សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ជានារី គឺដូចគ្នាគ្រប់ចំណុចទាំងអស់ទៅនឹងគ្រប់ឋានន្តរសក្តិសម្រាប់បុរសដែរ ខុសគ្នាតែពីទំហំប៉ុណ្ណោះគឺ ÷

-សក្តិចុងកអាវ : អាចមានទទឹងពី ៣ ទៅ ៣,៥០ សង់ទីម៉ែត្រ អាស្រ័យលើមាឌនារី

-សក្តិស្មា : អាចមានទំហំ ៨០% ឬ ៨៥% ឬ ៩០% នៃសក្តិស្មារបស់បុរស អាស្រ័យលើមាឌរបស់នារី

-សក្តិចុងដៃអាវ : អាចមានទំហំទទឹងស្មើនឹង ៧០% ទៅ ៧៥% នៃសក្តិចុងដៃអាវរបស់បុរស អាស្រ័យលើមាឌរបស់នារី

# ជំពូកទី ៣

## អំពីឯកសណ្ឋាន និង ការប្រើប្រាស់

**មាត្រា ៥.-**

ឯកសណ្ឋានសម្រាប់សម្គាល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ដែលបម្រើការងារនៅអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកំណត់ដូចខាងក្រោម ÷

**១ . ឯកសណ្ឋានផ្លូវការ**

**ក . ចំពោះបុរស**

-អាវកុដពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំគ្មានផែកខ្នង ។ ចុងកអាវទាំងសងខាង មានសក្តិចុងកអាវតាមឋានន្តរសក្តិ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិមួយគូ ។ នៅចុងដៃអាវមានសក្តិចុងដៃអាវតាមឋានន្តរសក្តិ ។ អាវនេះមានហោប៉ៅចោះបង្កប់ចំនួន ០៤ នៅខាងលើពីរ និង នៅខាងក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិ៍ស្រួចចំកណ្តាលចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ហារពណ៌មាស ឬ ប្រាក់ទៅតាមក្របខ័ណ្ឌ ( ពណ៌មាសសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល ពណ៌ប្រាក់សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌឧបការី ) ដែលមានអង្កត់ផ្ចិតប្រវែង ០១.៨០ សង់ទីម៉ែត្រ ។ អាវកុដពណ៌សនេះ មានបិទឡេវរូបព្រះសង្ហារចំនួន០៧ ពណ៌មាស ឬ ពណ៌ប្រាក់ទៅតាមក្របខ័ណ្ឌ ហើយឡេវនីមួយៗមានអង្កត់ផ្ចិតប្រវែង ០២.៥០ សង់ទី ម៉ែត្រ ។

-ខោជើងវែងពណ៌ ស តចង្កេះ ភ្ជិបកក្រោយខាងឆ្វេង ០២ ខាងស្តាំ ០២ ហោប៉ៅចំហៀងនៅសងខាង និងហោប៉ៅចោះក្រោយ ០១ នៅខាងស្តាំ ។

-ស្បែកជើងឃ្លុបកខ្លី ពណ៌ខ្មៅចងខ្សែ និង ស្រោមជើងពណ៌ខ្មៅ ។

**ខ . ចំពោះនារី**

-អាវជីបរាង ពណ៌ស ដោយប្រើសាច់ក្រណាត់ដូចឈុតអាវបុរសដែរ កត្រង់ គ្មានផែកខ្នង មានឡេវមុខរូបព្រះសង្ហារពណ៌មាស ឬ ប្រាក់ទៅតាមក្របខ័ណ្ឌ ចំនួន ០៥ មានអង្កត់ផ្ចិតប្រវែង ០២.៥០សង់ទីម៉ែត្រ ។ ចុងកអាវទាំងសងខាងមានសក្តិចុងកអាវតាមឋានន្តរសក្តិ ។ នៅលើស្មាមានបន្ទះសម្រាប់ដាក់សក្តិមួយគូ មានហោប៉ៅចោះចំនួន ០៤ នៅខាងលើពីរ និង នៅខាងក្រោមពីរ ដោយមានគម្របរាងស្លឹកពោធិ៍ ស្រួចចំកណ្តាលចោះរន្ធឡេវសម្រាប់បិទ ។ ដៃអាវវែងត្រឹមភ្នែកគោលដៃ ចុងដៃអាវមានសក្តិតាមឋានន្តរសក្តិ ។

-សំពត់សំឡយអំពីជាមួងពណ៌ខៀវ មានសម្រុងលើភ្នែកគោលនៃស្មងជើងប្រវែងពី ១០ ទៅ ១៥ សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌ និង កម្ពស់ ។

-ស្បែកជើងអេស្កាប៉ាង ឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែង ពណ៌សសម្រាប់ពេលព្រឹកដល់ថ្ងៃត្រង់ និងពណ៌ខ្មៅសម្រាប់ពេលល្ងាច ។

**រូបគំនូរឯកសណ្ឋានផ្លូវការសម្រាប់បុរស និង នារី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យនេះ ។**

**២ . ឯកសណ្ឋានប្រពៃណីជាតិ**

**ក . ចំពោះបុរស**

-អាវកុជពណ៌ស កត្រង់ ដៃវែង កាត់រាងអាវធំគ្មានឆែកខ្នង ។ ចុងកអាវទាំងសងខាង មានសក្តិចុងកអាវតាមឋានន្តរសក្តិ មានបន្ទះលើស្មាសម្រាប់ដាក់សក្តិមួយគូ ។ នៅចុងដៃអាវមានសក្តិចុងដៃអាវតាមឋានន្តរសក្តិ ។ អាវនេះមានហោប៉ៅចោះបង្កប់ចំនួន ០៤ នៅខាងលើពីរ និង នៅខាងក្រោមពីរ ដែលមានគម្របរាងស្លឹកពោធិ៍ស្រួចចំកណ្តាលចោះរន្ធឡេវសម្រាប់បិទ ហើយនៅលើគម្របហោប៉ៅទាំងបួននោះមានឡេវរូបព្រះសង្ហារពណ៌មាស ដែលមានអង្កត់ផ្ចិតប្រវែង ០១,៨០ សង់ទីម៉ែត្រ ។ អាវកុជពណ៌សនេះ មានបិទឡេវរូបព្រះសង្ហារ ចំនួន០៧ ពណ៌មាស ហើយឡេវនីមួយៗមានអង្កត់ផ្ចិតប្រវែង ០២,៥០ សង់ទីម៉ែត្រ។

-សំពត់ផាមួងចងក្បិន ពណ៌តាមថ្ងៃ ។

-ស្បែកជើងឃ្លុបពណ៌ខ្មៅ កខ្លី មានចងខ្សែ និង ស្រោមជើងពណ៌ខ្មៅដល់ក្បាលជង្គង់ ។

**ខ . ចំពោះនារី**

-អាវជីបរាង ពណ៌ " ស " ដៃវែងត្រឹមភ្នែកគោលដៃ កវៀលមូលខាងមុខធ្លាក់ចុះពីក្បាលឆ្អឹងដងកាំបិតប្រវែង ០១,៥០ សង់ទីម៉ែត្រ និង ត្រង់ស្មាឃ្លាតពីគល់កប្រមាណ ០២,៥០ ទៅ ០៣,០០ សង់ទីម៉ែត្រ អាស្រ័យទៅតាមមាឌរបស់នារី ។ អាវនេះ គ្មានសក្តិស្មា និង សក្តិចុងកអាវ ប៉ុន្តែមានសក្តិចុងដៃអាវទាំងសងខាង តាមក្របខ័ណ្ឌ និងឋានន្តរសក្តិ។

-ពានាក្រមាពណ៌តាមសំពត់ ។ សាច់ក្រមា ដែលធ្វើអំពីសូត្រ មានផ្ទៃពណ៌ខ្ចីជាងសំពត់ ឬ ពានាក្រមាពណ៌ស៊ីន្ទូន ឬ តាមពិធីការ កំណត់ ហើយនៅលើក្រមាពានាផ្នែកខាងឆ្វេងនៃដើមទ្រូង ត្រូវក្លាស់ "សក្តិកន្លាស់ " ជាសញ្ញាសម្គាល់សម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល ។

-សំពត់ផាមួងចងក្បិនពណ៌តាមថ្ងៃ

-ស្បែកជើងឃ្លុបមុខ ឃ្លុបក្រោយ គ្មានចងខ្សែ មានកែង ពណ៌សសម្រាប់ពេលព្រឹកដល់ថ្ងៃត្រង់ និង ពណ៌ខ្មៅសម្រាប់ពេលល្ងាច ។

-កាបូបយួរដៃពណ៌ស ឬ ពណ៌ខ្មៅ( មិនឱ្យស្ពាយទេ ) ស្របតាមការប្រើស្បែកជើងពណ៌ស ឬ ពណ៌ខ្មៅ ។

**រូបគំនូរឯកសណ្ឋានប្រពៃណីជាតិសម្រាប់បុរស និង នារី មានគំរូដូចក្នុងឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យនេះ ។**

**មាត្រា ៦.-**

ការប្រើប្រាស់ឯកសណ្ឋានសម្រាប់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការី ត្រូវបានកំណត់ដូចខាងក្រោម ÷

-ឯកសណ្ឋានផ្លូវការ សម្រាប់ប្រើប្រាស់ក្នុងឱកាសទទួលគ្រឿងឥស្សរិយយស ទិវាបុណ្យជាតិ និង ពិធីផ្លូវការផ្សេងៗទៀតរបស់រដ្ឋ ឬ តាមការកំណត់របស់ថ្នាក់ដឹកនាំស្ថាប័ន។

-ឯកសណ្ឋានប្រពៃណីជាតិសម្រាប់ប្រើប្រាស់ក្នុងទិវាបុណ្យប្រពៃណីជាតិ និង សាសនា ដែលប្រារព្ធធ្វើឡើងនៅក្នុងព្រះបរមរាជវាំង ឬ ក្នុងវត្តអារាម ឬ ទីកន្លែងផ្សេងៗ ត្រូវបានកំណត់ឱ្យប្រើសម្រាប់តែមន្ត្រីរាជការក្របខ័ណ្ឌអភិបាល ដែលមានឋានន្តរសក្តិឧត្តមអភិបាល ។

ឯកសណ្ឋានទាំងពីរប្រភេទខាងលើនេះ ក៏ត្រូវស្លៀកពាក់ទៅតាមការកំណត់ក្នុងសេចក្តីអញ្ជើញជាផ្លូវការរបស់គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ-អន្តរជាតិ ឬ ក្រសួងព្រះបរមរាជវាំង ។

## ជំពូកទី ៤
## របបកំណត់សញ្ញាសក្តិ និង ឯកសណ្ឋាន

**មាត្រា ៧.-**

សញ្ញាសក្តិ ឯកសណ្ឋានផ្លូវការ ឯកសណ្ឋានប្រពៃណីជាតិ និង សម្ភារៈផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ត្រូវបានផ្តល់ជូនដល់មន្ត្រីរាជការក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីមួយសម្រាប់ក្នុងម្នាក់ៗ សម្រាប់រយៈពេល ០៣ ឆ្នាំ ។

ការចំណាយលើសញ្ញាសក្តិ ឯកសណ្ឋានគ្រប់ប្រភេទ និង សម្ភារៈផ្សេងៗទៀតដូចបានកំណត់ក្នុងព្រះរាជក្រឹត្យនេះ ជាបន្ទុកថវិការដ្ឋ ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា ៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៩.-**

ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវទទួលអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

**ព្រះហស្តលេខា និង ព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ពរល.០៦០៨.៣៨៨

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០០៦

លេខ : ០០៤ ចល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦

**អគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ**

ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ថ្នាក់សក្តិឧត្តមអភិបាល (ពណ៌មាស)



សក្តិចុងករអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ថ្នាក់ខ្ពស់សក្តិវរអភិបាល (ពណ៌មាស)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៣ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិអភិបាល (ពណ៌មាស)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៤ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ថ្នាក់ឋានន្តរសក្តិនាយឧបការី (ពណ៌ប្រាក់)



**សក្តិចុងកអាវ**



**សក្តិស្មា**



**សក្តិចុងដៃអាវ**

ឧបសម្ព័ន្ធទី ៥ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិឧបការីជើងខ្សែ (ពណ៌ប្រាក់)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៦ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សញ្ញាសក្តិមន្ត្រី ឋានន្តរសក្តិឧបការី (ពណ៌ប្រាក់)



សក្តិចុងកអាវ



សក្តិស្មា



សក្តិចុងដៃអាវ

ឧបសម្ព័ន្ធទី ៧ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## សក្តិកន្លាស់



សម្រាប់ក្របខ័ណ្ឌអភិបាល ពណ៌មាស



សម្រាប់ក្របខ័ណ្ឌឧបការី ពណ៌ប្រាក់

ឧបសម្ព័ន្ធទី ៨ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥
ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី
ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ

## ឯកសណ្ឋានផ្លូវការសម្រាប់បុរស និង នារី



**ឧបសម្ព័ន្ធទី ៩ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០៨០៦/៣៦៥**

**ចុះថ្ងៃទី ២៩ ខែ សីហា ឆ្នាំ២០០៦ ស្តីពីសញ្ញាសក្តិ និង ឯកសណ្ឋានមន្ត្រី**

**ក្របខ័ណ្ឌអភិបាល និង ក្របខ័ណ្ឌឧបការីនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ**

# ឯកសណ្ឋានប្រពៃណីជាតិ សម្រាប់បុរស និង នារី

# (ឋានន្តរសក្តិឧត្តមអភិបាលនៃក្របខ័ណ្ឌអភិបាល)



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៩០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតការិយាល័យអនុព័ន្ធយោធា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើត ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ នឹងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជា អគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- យោងតាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងការពារជាតិ

## ស ម្រេ ច

**មាត្រា១** : ត្រូវបានបង្កើតការិយាល័យអនុព័ន្ធយោធាអមស្ថានទូតកម្ពុជា ប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី

**មាត្រា២** : ការិយាល័យអនុព័ន្ធយោធាអមស្ថានទូតកម្ពុជាប្រចាំសាធារណរដ្ឋឥណ្ឌូនេស៊ី ដឹកនាំដោយអនុព័ន្ធយោធាមួយរូប និង អមដោយជំនួយការមួយរូប ដែលត្រូវតែងតាំងដោយ រដ្ឋមន្ត្រីក្រសួងការពារជាតិ ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ កញ្ញា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ: ៧១ អនក្រ.បក**

# អនុក្រឹត្យ

## ស្តីពី

## ការប្រែក្លាយវិទ្យាស្ថានជាតិសុខភាពសាធារណៈ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ របស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៦

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

វិទ្យាស្ថានជាតិសុខភាពសាធារណៈសរសេរកាត់ថា **វ.ជ.ស.ស.** ដែលមានឈ្មោះដើមហៅថាវិទ្យាស្ថានជាតិស្រាវជ្រាវសុខភាពសាធារណៈ ត្រូវបានសម្រេចឱ្យប្រែក្លាយទៅជាគ្រឹះស្ថានសាធារណរដ្ឋបាល ស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស របស់ក្រសួងសុខាភិបាល និង ស្ថិតនៅក្រោមអាណាព្យាបាលហិរញ្ញវត្ថុ របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**មាត្រា ២.-**

**វ.ជ.ស.ស.** ជានីតិបុគ្គល និង មានស្វ័យភាព ហិរញ្ញវត្ថុ ។ **វ.ជ.ស.ស.** មានអាសយដ្ឋានជីឡូត៍លេខ ២ មហាវិថី គីមអ៊ីលស៊ុង សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ការផ្លាស់ប្តូរអាសយដ្ឋាន នៅពេលអនាគតជាសមត្ថកិច្ចរបស់ **វ.ជ.ស.ស.** ។

**មាត្រា ៣.-**

**វ.ជ.ស.ស.** មានភារកិច្ចជាអាទិ៍ដូចតទៅ:

- បណ្តុះបណ្តាលមុខជំនាញសុខភាពសាធារណៈ កម្រិត ក្រោយឧត្តមសិក្សា ជូនដល់មន្ត្រីសុខាភិបាល និង អ្នកដែលមានជំនាញសុខាភិបាល
- សិក្សាស្រាវជ្រាវសុខភាពសាធារណៈ ទាក់ទងនឹងប្រព័ន្ធសុខាភិបាល អេពីដេមីសាស្ត្រ និង វេជ្ជសាស្ត្រ
- ផ្តល់សេវាប្រឹក្សាសុខភាពសាធារណៈ ដែលពាក់ព័ន្ធការបណ្តុះបណ្តាល និង អប់រំសុខភាពសាធារណៈ ការស្រាវជ្រាវសុខភាពសាធារណៈ និង ការអភិវឌ្ឍប្រព័ន្ធសុខាភិបាល
- ផ្តល់សេវាអមវេជ្ជសាស្ត្រ
- តម្កល់ និងផ្តល់ឯកសារព័ត៌មានទាក់ទងសុខភាពសាធារណៈ
- ជាសេនាធិការជំនួយឱ្យក្រសួងសុខាភិបាល លើការងារអភិវឌ្ឍវិស័យសុខាភិបាលសាធារណៈ
- គ្រប់គ្រងមន្ត្រីរាជការ និយោជិក កម្មករ និង ទ្រព្យសម្បត្តិរដ្ឋរបស់ **វ.ជ.ស.ស.**
- ទាក់ទងសហប្រតិបត្តិការជាមួយអង្គការជាតិ-អន្តរជាតិ និង ស្ថាប័ននានាដែលពាក់ព័ន្ធ ។

## ជំពូកទី ២
## រដ្ឋបាល និង ការគ្រប់គ្រង
### ផ្នែកទី ១
### ក្រុមប្រឹក្សាភិបាល

**មាត្រា ៤.-**

**វ.ជ.ស.ស** ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលមួយ ដែលមានសិទ្ធិទូលំទូលាយ ដើម្បីធ្វើសកម្មភាពការងារក្នុងក្របខ័ណ្ឌបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ និងបទបញ្ជាផ្ទៃក្នុងរបស់ **វ.ជ.ស.ស.** ។

**មាត្រា ៥.-**

៥.១ - ក្រុមប្រឹក្សាភិបាលមានសមាជិក ០៧ ( ប្រាំពីរ) រូប ដែលមានសមាសភាពដូចតទៅ ÷

- តំណាងក្រសួងសុខាភិបាល ប្រធាន
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
- តំណាងក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- នាយកវិទ្យាស្ថានជាតិសុខភាពសាធារណៈ សមាជិកស្វ័យប្រវត្តិ
- ឥស្សរជនមានចំណេះដឹង និង បទពិសោធខាងវិទ្យាសាស្ត្រសុខាភិបាល សមាជិក
- តំណាងបុគ្គលិកនៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ សមាជិកស្វ័យប្រវត្តិ

៥.២-តំណាងបុគ្គលិកនៃវិទ្យាស្ថានជាតិសុខភាពសាធារណៈ ត្រូវជ្រើសរើសដោយការបោះឆ្នោត ក្នុងចំណោមបុគ្គលិក **វ.ជ.ស.ស.** សម្រាប់អាណត្តិនីមួយៗ ។

៥.៣-ប្រធាន និង សមាជិកក្រុមប្រឹក្សាភិបាល ដែលមិនមែនជាសមាជិកស្វ័យប្រវត្តិ ត្រូវបានតែងតាំងដោយ អនុក្រឹត្យ សម្រាប់អាណត្តិ ០៣(បី)ឆ្នាំ តាមសំណើរបស់ក្រសួង ឬ ស្ថាប័ន ដែលខ្លួនតំណាងឱ្យ ។ អាណត្តិនេះអាចបញ្ចប់បានគ្រប់ពេលវេលា ដោយអនុក្រឹត្យតាមសំណើនៃក្រសួង ឬ ស្ថាប័នដែលខ្លួនតំណាងឱ្យ ។

**មាត្រា ៦.-**

សមាជិកក្រុមប្រឹក្សាភិបាល ត្រូវជ្រើសរើសក្នុងចំណោមមន្ត្រី ដែលសកម្មធ្លាប់បានបម្រើការងារយ៉ាងតិច ០៥ ( ប្រាំ) ឆ្នាំ ឬ ជាឥស្សរជនដែលមានបទពិសោធគ្រប់គ្រាន់ ព្រមទាំងមានជំនាញខ្ពស់ ក្នុងវិស័យសេដ្ឋកិច្ចវិទ្យាសាស្ត្រសុខាភិបាល អប់រំ ឬ នីតិសាស្ត្រ ដែលមានសញ្ជាតិខ្មែរ និង មានលិខិតថ្កោលទោសបញ្ជាក់ថា ពុំដែលបានទទួលទណ្ឌកម្មកម្រិតធ្ងន់ ពីតុលាការឡើយ ។

**មាត្រា ៧.-**

៧.១-ប្រធានក្រុមប្រឹក្សាភិបាលមានតួនាទី កោះប្រជុំនិងកំណត់របៀបវារៈនៃអង្គប្រជុំ របស់ក្រុមប្រឹក្សាភិបាល។

៧.២-ប្រធានក្រុមប្រឹក្សាភិបាល អាចអញ្ជើញឥស្សរជននៅក្រៅក្រុមប្រឹក្សាភិបាល ដែលមានបទពិសោធលើវិស័យស្រាវជ្រាវអប់រំ និងបណ្តុះបណ្តាលសុខភាពសាធារណៈ និងតំណាងអ្នកផ្តល់ជំនួយ ឬ ដៃគូអភិវឌ្ឍចូលរួម ក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល ។ ឥស្សរជនទាំងនោះ មានសិទ្ធិផ្តល់មតិ តែពុំមានសិទ្ធិបោះឆ្នោតឡើយ ។

**មាត្រា ៨.-**

ក្រុមប្រឹក្សាភិបាល មានបេសកកម្មដឹកនាំ តម្រង់ទិសដៅ និងធ្វើការត្រួតពិនិត្យ លើដំណើរការរបស់វិទ្យាស្ថាន ។ ក្នុងក្របខ័ណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ ÷

- ពិនិត្យ និង សម្រេចលើគម្រោងផែនការអភិវឌ្ឍនៃ **វ.ជ.ស.ស.** ស្របតាមទិសដៅកំណត់របស់រាជរដ្ឋាភិបាល
- ពិនិត្យ និង សម្រេចលើគម្រោងផែនការសកម្មភាពនៃ **វ.ជ.ស.ស.**
- ពិនិត្យ និង សម្រេចលើចំណូល និង ចំណាយជាប្រចាំព្រមទាំងទុន ក្នុងថវិកាប្រចាំឆ្នាំ របស់ **វ.ជ.ស.ស.**

- ពិនិត្យ និង សម្រេចលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- កំណត់ការរៀបចំរចនាសម្ព័ន្ធ និងការបែងចែកភារកិច្ចជាទូទៅ ដល់គ្រប់ការិយាល័យ និងអង្គភាពក្រោមឱវាទនិងធ្វើការអភិវឌ្ឍតាមការចាំបាច់
- កំណត់នូវរបបជ្រើសរើសការតម្លើងឋានន្តរសក្តិ ឬការផ្តល់លាភការ ដល់បុគ្គលិក **ទ.ទ.ស.ស.**ដោយពុំប៉ះពាល់ដល់បទប្បញ្ញត្តិច្បាប់ ឬ បទបញ្ជាផ្ទៃក្នុងដែលអនុវត្ត ចំពោះភ្នាក់ងារមុខងារសាធារណៈ
- សម្រេចលើក្របខ័ណ្ឌចំនួនបុគ្គលិក ដែលអនុញ្ញាតសម្រាប់ **ទ.ទ.ស.ស.**
- សម្រេចលើកិច្ចសន្យា ស្តីពីលទ្ធកម្មសាធារណៈ ដោយអនុវត្តតាមបទប្បញ្ញត្តិ នៃលទ្ធកម្មសាធារណៈ
- កំណត់បទបញ្ជាផ្ទៃក្នុងនៃ **ទ.ទ.ស.ស.**
- ធ្វើការវាយតម្លៃតាមចន្លោះពេលទៀងទាត់ លើកម្រិតលទ្ធផលសម្រេចបាន តាមគោលដៅកំណត់ដោយ **ទ.ទ.ស.ស.** ហើយកំណត់នូវវិធានការកែតម្រូវ ដើម្បីអនុវត្ត ។

**មាត្រា ៩.-**

លាភការរបស់សមាជិកក្រុមប្រឹក្សាភិបាល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ ក្រុមប្រឹក្សាភិបាល ក្រោយពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ១០.-**

១០.១-ក្រុមប្រឹក្សាភិបាល នៃ **ទ.ទ.ស.ស.** ត្រូវធ្វើការប្រជុំយ៉ាងតិចមួយត្រីមាសម្តង តាមការអញ្ជើញ របស់ប្រធាន ឬ តាមការស្នើរបស់សមាជិកចំនួន ២/៣ (ពីរភាគបី) ឡើងទៅ ឬ តាមការស្នើសុំរបស់នាយក នៃ **ទ.ទ.ស.ស.** ។ ក្នុងករណីមានធុរៈប្រធាន ត្រូវផ្ទេរសិទ្ធជូនសមាជិកណាម្នាក់ក្នុងចំណោម សមាជិករបស់ ក្រុមប្រឹក្សាភិបាល ដើម្បីដឹកនាំការប្រជុំ ។ ប្រធានអង្គប្រជុំត្រូវជ្រើសរើសលេខាធិការនៃអង្គប្រជុំ ០១ (មួយ) រូប ដែលមិនមែនជា សមាជិកក្រុមប្រឹក្សាភិបាល។ លេខាធិការនេះគ្មានសិទ្ធិបោះឆ្នោតទេ ។ របៀបវារៈ ព្រមទាំងឯកសារទាំងឡាយ ត្រូវផ្ញើជូនគ្រប់សមាជិក នៃក្រុមប្រឹក្សាភិបាល និងគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដែលមាន ចែងក្នុងអនុក្រឹត្យនេះយ៉ាងតិច ១០(ដប់) ថ្ងៃ មុនថ្ងៃប្រជុំ។

១០.២-ការប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចនឹងយកជាការបាន លុះត្រាតែមានសមាជិកចំនួនលើសពី ៥០ (ហាសិប) ភាគរយ នៃសមាជិកទាំងអស់។ សមាជិកអវត្តមាន គ្មានសិទ្ធិបញ្ជូនតំណាងឱ្យមកប្រជុំជំនួសខ្លួនបានឡើយ។ ប្រសិនបើសម្លេងកូរ៉ុមមិនគ្រប់ចំនួនទេ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំម្តងទៀត យ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយថ្ងៃប្រជុំលើកមុន ហើយការប្រជុំលើកក្រោយនេះ មិនចាំបាច់តម្រូវឱ្យមានគ្រប់កូរ៉ុមឡើយ ហើយត្រូវពិភាក្សាតែលើរបៀបវារៈ នៃការអញ្ជើញប្រជុំលើកទីមួយ។ សមាជិកវត្តមាន ត្រូវចុះហត្ថលេខា លើបញ្ជីវត្តមានមួយ។ សេចក្តីសម្រេចទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលអាចយកជាការបាន លុះត្រាតែមានការអនុម័ត ដោយសម្លេងភាគច្រើននៃសមាជិកវត្តមាន។ ក្នុងករណីមានសម្លេងស្មើគ្នា សម្លេងប្រធានអង្គប្រជុំ ចាត់ទុកជាឧត្តមានុភាព ។

១០.៣-សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវកត់ត្រាក្នុងកំណត់ហេតុមួយ តម្កល់ទុកនៅទីស្នាក់ការ របស់ **ទ.ទ.ស.ស.** និង ត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ និងលេខាធិការអង្គប្រជុំ ។ កំណត់ហេតុនេះ ត្រូវបង្ហាញនូវ

-

អត្ថន័យ នៃការពិភាក្សាឱ្យបានច្បាស់លាស់ និងត្រូវផ្ញើជូនសមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ និងត្រូវផ្ញើជូន ក្រសួងពាក់ព័ន្ធ យ៉ាងយូរ ១០ (ដប់) ថ្ងៃក្រោយពេលប្រជុំ ។

១០.៤-**វ.ជ.ស.ស.**ត្រូវផ្ញើជូន ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ នូវឯកសារដូចតទៅ÷

- កំណត់ហេតុ នៃការប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ផែនការអភិវឌ្ឍរបស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ
- ថវិកាប្រចាំឆ្នាំ
- របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ។

១០.៥- ឯកសារទាំងនេះ ត្រូវបញ្ជូនទៅអ្នក ដែលត្រូវទទួលក្នុងរយៈពេលមិនឱ្យហួសពី ១៥ (ដប់ប្រាំ) ថ្ងៃ ។

## ផ្នែកទី ២

## អង្គការប្រតិបត្តិរបស់វិទ្យាស្ថាន

**មាត្រា ១១.-**

**វ.ជ.ស.ស.** ត្រូវគ្រប់គ្រងដោយនាយកវិទ្យាស្ថានមួយរូប ដែលត្រូវបានតែងតាំងដោយអនុក្រឹត្យ តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ នាយកវិទ្យាស្ថានរូបនេះមានតួនាទីជានាយកប្រតិបត្តិ ។

**មាត្រា ១២.-**

១២.១-នាយកនៃ **វ.ជ.ស.ស.**មានសិទ្ធិពេញលេញ ដើម្បីគ្រប់គ្រង និងអនុវត្តការងារ ដែលមានចែងក្នុង អនុក្រឹត្យនេះ លើកលែងតែកិច្ចការ ដែលជាសមត្ថកិច្ចរបស់ក្រុមប្រឹក្សាភិបាល ។

នាយកនៃ **វ.ជ.ស.ស.**មានភារកិច្ច÷

- រៀបចំការងារអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទទួលបន្ទុកអនុវត្តសេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាល ព្រមទាំងដាក់ឱ្យដំណើរការ នូវគោលនយោបាយ ដែលកំណត់ដោយក្រុមប្រឹក្សានេះ
- រៀបចំថវិកា ប្រចាំឆ្នាំសម្រាប់ **វ.ជ.ស.ស.** ហើយដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច
- ធ្វើរបាយការណ៍ការងារគ្រប់គ្រងប្រចាំឆ្នាំត្រួតពិនិត្យលើគណនីហិរញ្ញវត្ថុប្រចាំឆ្នាំ និងដាក់ឯកសារ ទាំងនេះ ជូនក្រុមប្រឹក្សាភិបាលពិនិត្យ
- ធ្វើការបញ្ជាក់ក្នុងករណីចាំបាច់ លើភារកិច្ចរបស់បណ្តាការិយាល័យក្រោមឱវាទ
- បំពេញរាល់មុខតំណែងរបស់ **វ.ជ.ស.ស** ក្នុងការកម្រិតក្របខ័ណ្ឌចំនួនបុគ្គលិក ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ព្រមទាំងគោរពតាមវិធានការ ស្តីពីការគ្រប់គ្រងបុគ្គលិក
- បំពេញតួនាទីតាមឋានានុក្រមចំពោះបុគ្គលិកទាំងអស់របស់ **វ.ជ.ស.ស.**ដែលកំណត់ដោយក្រុមប្រឹក្សាភិបាល ស្តីពីការបែងចែកសិទ្ធិអំណាច និងទៅតាមបទបញ្ជាផ្ទៃក្នុង ព្រមទាំងបទប្បញ្ញត្តិដទៃទៀត ស្តីពីបញ្ហានេះជារួម គឺបំពេញរាល់មុខងាររដ្ឋបាល និងគ្រប់គ្រងការងារទាំងឡាយ ដែលត្រូវបានប្រគល់

ឱ្យតាមបទបញ្ជា ផ្ទៃក្នុងរបស់ **ទ.ជ.ស.ស.** និង តាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

១២.២-នាយកនៃ **ទ.ជ.ស.ស.** ជាតំណាងរបស់វិទ្យាស្ថាន ក្នុងការទាក់ទងជាមួយតតិយជន ។

១២.៣-នាយកនៃ **ទ.ជ.ស.ស.** ត្រូវស្នើទៅក្រសួងសុខាភិបាល តាមរយៈក្រុមប្រឹក្សាភិបាលសុំតែងតាំងនាយករងមួយចំនួន។ នាយក និងនាយករង ត្រូវមានចំណេះដឹងលើផ្នែកគ្រប់គ្រង។

## ផ្នែកទី ៣

## បុគ្គលិករបស់ " ទ.ជ.ស.ស "

**មាត្រា ១៣.-**

១៣.១-បុគ្គលិកអចិន្ត្រៃយ៍របស់ **ទ.ជ.ស.ស.** មានមន្ត្រីរាជការក្របខ័ណ្ឌមុខងារសាធារណៈ មកពីក្រសួងសុខាភិបាល ឬ មកពីក្រសួងស្ថាប័នរដ្ឋដទៃទៀត។ មន្ត្រីទាំងឡាយនេះត្រូវបានរក្សាទុកនូវក្របខ័ណ្ឌប្រាក់បៀវត្ស និងប្រាក់កម្រៃ ផ្សេងៗ ដែលបានកំណត់ដោយមុខងារសាធារណៈ ពីអង្គភាពដើមរបស់ខ្លួន ។

១៣.២-វិទ្យាស្ថានអាចជ្រើសរើសបុគ្គលិកជាប់កិច្ចសន្យាជំនួយការ និងពលករអណ្តែត ។ បុគ្គលិកទាំងនេះត្រូវ ស្ថិតនៅក្រោមបទប្បញ្ញត្តិនៃបទបញ្ជាផ្ទៃក្នុង និងតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ ស្តីពីការងារ ។

១៣.៣-បុគ្គលិក **ទ.ជ.ស.ស.** ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងនៃបទបញ្ជា ស្តីពីការគ្រប់គ្រងបុគ្គលិក ដែលបានសម្រេចដោយក្រុមប្រឹក្សាភិបាល ។ ក្រុមប្រឹក្សាភិបាលកំណត់ប្រាក់កម្រៃលើកទឹកចិត្តចំពោះបុគ្គលិក ព្រមទាំងបែបបទនៃការទទាត់ផង ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុង។

## ផ្នែកទី ៤

## ទ្រព្យសម្បត្តិរបស់ ទ.ជ.ស.ស.

**មាត្រា ១៤.-**

១៤.១-**ទ.ជ.ស.ស.** ទទួលដើមទុនដំបូងពីរដ្ឋ នូវដីធ្លី និងអចលនវត្ថុ ដែលមានបញ្ជាក់ក្នុងតារាងឧបសម្ព័ន្ធ តាមបញ្ជីសារពើភ័ណ្ឌចុងក្រោយ ដែលផ្ទៃដីមានប្រមាណជា១៥,៩៥០.០០ម² ស្ថិតនៅដីឡូតិ៍លេខ២ សង្កាត់បឹងកក់២ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

១៤.២-**ទ.ជ.ស.ស.** អាច ទិញ ប្តូរ លក់ ចលនទ្រព្យ ។ **ទ.ជ.ស.ស.** អាច ទិញ ប្តូរ លក់ អចលនទ្រព្យចាំបាច់សម្រាប់ ដំណើរការរបស់វិទ្យាស្ថាន ដោយមានការឯកភាពពីក្រសួងអាណាព្យាបាលទាំងពីរ និងស្របតាមច្បាប់ជាធរមាន។

## ផ្នែកទី ៥

## ការគ្រប់គ្រងហិរញ្ញវត្ថុ និង គណនេយ្យរបស់ ទ.ជ.ស.ស.

**មាត្រា ១៥.-**

ការគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យ នៃ **ទ.ជ.ស.ស.** ត្រូវប្រព្រឹត្តស្របតាមគោលការណ៍ នៃ គណនេយ្យសាធារណៈ ដូចមានចែងក្នុងមាត្រា ១២២ នៃអនុក្រឹត្យលេខ ៨២ អនក្រ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ញាទូទៅនៃគណនេយ្យសាធារណៈ ។

**មាត្រា ១៦.-**

១៦.២-នាយក នៃ **ទ.ជ.ស.ស.** ជាអាណាប័កដើមខ្សែ របស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ ហើយត្រូវមានភារកិច្ច ÷

- ពិនិត្យប្រាក់ និងទូទាត់ចំណូល
- ចាត់ចែងធ្វើការទូទាត់ និងចេញបញ្ជាចំណាយ

១៦.២-អាណាប័កដើមខ្សែ អាចផ្ទេរសិទ្ធិឱ្យអាណាប័កផ្ទេរសិទ្ធិ ឬអាចបង្កើតនូវរជ្ជទេយ្យចំណូល ឬបុរេប្រទានបានដោយមានការព្រមព្រៀង ពីភ្នាក់ងារគណនេយ្យរបស់ **ទ.ជ.ស.ស.** ។

**មាត្រា ១៧.-**

១៧.១-ការគ្រប់គ្រងហិរញ្ញវត្ថុ និងការកាន់កាប់គណនេយ្យ ត្រូវអនុវត្តដោយអនុលោមទៅតាមបទបញ្ជាផ្ទៃ ក្នុងរបស់ **ទ.ជ.ស.ស.** ក្រោមការទទួលខុសត្រូវផ្ទាល់របស់ភ្នាក់ងារគណនេយ្យ ។ ភ្នាក់ងារគណនេយ្យ នេះត្រូវតែងតាំងដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដោយត្រូវធ្វើសច្ចាប្រណិធាន មុនចូលកាន់ការងារ ។ ភ្នាក់ងារគណនេយ្យនេះ ត្រូវចូលរួមក្នុងការប្រជុំរបស់ក្រុមប្រឹក្សាភិបាល ក្នុងឋានៈជាអ្នកពិគ្រោះយោបល់ តែឥតមានសម្លេងឆ្នោតឡើយ ។

១៧.២- ភ្នាក់ងារគណនេយ្យមានភារកិច្ច ÷

- ប្រមូលចំណូល
- បើកប្រាក់ចំណាយ
- រក្សាទុក និង ចាត់ចែងប្រើប្រាស់នូវមូលនិធិ និងធនធានរបស់ **ទ.ជ.ស.ស.**
- រក្សាទុកនូវលិខិតយុត្តិការ និង កាន់កាប់បញ្ជីគណនេយ្យ

១៧.៣- ភ្នាក់ងារគណនេយ្យ អាចផ្ទេរសិទ្ធិខ្លះ ទៅឱ្យអាជ្ញានុកររីរបស់ខ្លួន ។

**មាត្រា ១៨.-**

១៨.១-ប្រភពធនធានរបស់ **ទ.ជ.ស.ស.**រួមមាន ÷

- ធនធានដំបូងរបស់រដ្ឋផ្តល់ដល់ **ទ.ជ.ស.ស** នៅពេលផ្តើមបង្កើតដំបូង
- ឧបត្ថម្ភធនសម្រាប់ដំណើរការ និងឧបត្ថម្ភធនជាមូលធន ដែលមានចែងក្នុងថវិការដ្ឋ
- អំណោយ ជំនួយ និង អច្ច័យទានដែល **ទ.ជ.ស.ស.** បានទទួល
- ប្រាក់ខ្ចីបុលដោយផ្ទាល់ និងប្រាក់ដែលរដ្ឋខ្ចីបុលឱ្យ **ទ.ជ.ស.ស.**
- ផលការងារ និងកម្រៃនៃការផ្តល់សេវាផ្សេងៗ ដោយ **ទ.ជ.ស.ស.**
- កម្រៃនៃទ្រព្យសម្បត្តិរបស់ **ទ.ជ.ស.ស.** និង ចំណូលនៃការលក់ទ្រព្យសម្បត្តិ ដែលបានទទួលការអនុញ្ញាតពីរាជរដ្ឋាភិបាល
- កម្រៃនៃទ្រព្យសម្បត្តិដែលបានប្រគល់ ឱ្យ **ទ.ជ.ស.ស.** ។

១៨.២-ចំណូលចំណាយជាប្រចាំព្រមទាំងមូលធន របស់ **វ.ជ.ស.ស.** ត្រូវបានគ្រោងក្នុងថវិកាប្រចាំឆ្នាំ របស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ ។ ក្រុមប្រឹក្សាភិបាលរបស់ **វ.ជ.ស.ស** ត្រូវចែងអំពីបែបបទនៃការរៀបចំចាត់ចែង និងអនុវត្តថវិកា ។ សេចក្តីសម្រេចទាំងឡាយ របស់ក្រុមប្រឹក្សាភិបាលទាក់ទងដល់ទម្រង់បែបបទ នៃការរៀបចំចាត់ចែង និងអនុវត្តថវិកាត្រូវមានការយល់ព្រម ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

១៨.៣-ថវិកាត្រូវរៀបចំដោយអាណាប័កដើមខ្សែ **វ.ជ.ស.ស.** ហើយត្រូវដាក់ជូនក្រុមប្រឹក្សាភិបាលដែលត្រូវធ្វើការសម្រេចយ៉ាងយូរត្រឹមថ្ងៃទី ៣០ ខែ កញ្ញា ក្នុងឆ្នាំនីមួយៗ ។ ថវិកាត្រូវតែធ្វើឱ្យមានលំនឹង រវាងចំណូលនិងចំណាយ ។

**មាត្រា ១៩.-**

១៩.១-ការងារគណនេយ្យរបស់ **វ.ជ.ស.ស.** រួមមាន ÷

- គណនេយ្យទូទៅត្រូវកាន់កាប់ជាគណនេយ្យទ្វេភាគ ដែលចែងអំពីប្រតិបត្តិការថវិកា រតនាគារ និង ប្រតិបត្តិការដែលអនុវត្តជាមួយតតិយជន
- គណនេយ្យ អសង្ហារឹម រូបធាតុ និងគណនេយ្យតម្លៃ
- គណនេយ្យវិភាគ ប្រសិនបើជាការចាំបាច់

គណនេយ្យ វិទ្យាស្ថានជាតិសុខភាពសាធារណៈត្រូវ ÷

- ស្របតាមវិធានដែលកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- គោរពតាមប្លង់គណនេយ្យរបស់ **វ.ជ.ស.ស.** ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល
- ប្លង់គណនេយ្យ នេះត្រូវបានការយល់ព្រម ពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

១៩.២-របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ របស់វិទ្យាស្ថានជាតិសុខភាពសាធារណៈ ត្រូវរៀបចំដោយភ្នាក់ងារ គណនេយ្យ និង អាណាប័កដើមខ្សែ ដោយភ្ជាប់ជាមួយរបាយការណ៍គ្រប់គ្រង ដើម្បីជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេចលើឯកសារទាំងនោះ យ៉ាងយូរ ៣ (បី)ខែ ក្រោយការបិទការិយបរិច្ឆេទគណនេយ្យ ។

**មាត្រា ២០.-**

មូលនិធិ **វ.ជ.ស.ស.** គឺជាមូលនិធិសាធារណៈ ដែលត្រូវដាក់ចូលក្នុងគណនីមួយ នៅក្នុងរតនាគារជាចាំបាច់ លើកលែងតែ មានបដិប្បញ្ញត្តិ ដែលត្រូវមានការយល់ព្រមតាមប្រកាស របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

## ជំពូកទី ៦

## របបសារពើពន្ធនៃ វ.ជ.ស.ស.

**មាត្រា ២១.-**

លើកលែងតែមានបដិប្បញ្ញត្តិដែលត្រូវមានចែងដោយច្បាប់ **វ.ជ.ស.ស.** ត្រូវស្ថិតនៅក្រោមនីតិរួមចំពោះរបបសារពើពន្ធ។

## ជំពូកទី ៧

## លទ្ធកម្មរបស់ វ.ជ.ស.ស.

**មាត្រា ២២.-**

ការសម្រេចការអនុវត្តនិងការត្រួតពិនិត្យលើលទ្ធកម្ម របស់ **វ.ជ.ស.ស.** ត្រូវគ្រប់គ្រងតាមបទប្បញ្ញត្តិទាំងឡាយជាធរមានពាក់ពន្ធ័នឹងបញ្ហានេះ ។

ជាបានការនូវការជំទាស់ទាំងនេះ សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ត្រូវបញ្ជាក់ពីមូលហេតុហើយត្រូវជម្រាបជូនដំណឹងជាបន្ទាន់ភ្លាម ស្តីពីបញ្ហានេះជាលាយលក្ខណ៍អក្សរដល់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ២៥.-**

២៥.១-រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចលុប ឬ ផ្អាកទុក នូវសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ឬ នាយកនៃ **វ.ជ.ស.ស.** ក្នុងករណីដែលសេចក្តីសម្រេចនោះ÷

- ផ្ទុយនឹងគោលដៅរបស់វិទ្យាស្ថាន
- ផ្ទុយនឹងច្បាប់ និង បទបញ្ជា
- ផ្ទុយនឹងបែបបទនៃការប្រជុំដែលមានចែងក្នុងមាត្រា ១០ នៃអនុក្រឹត្យនេះ។

២៥.២-ការលុបចោល ឬការផ្អាកទុកទាំងនេះ ត្រូវសម្រេចដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ដោយមានបញ្ជាក់ពីមូលហេតុតាមគំនិតផ្ទាល់ខ្លួន ឬ តាមបណ្តឹងពីភាគីនានាដែលពាក់ព័ន្ធ ។ ការលុបចោល ឬ ការផ្អាកទុកនូវសេចក្តី សម្រេចនេះ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់នាយកនៃ **វ.ជ.ស.ស.** ហើយនាយកវិទ្យាស្ថាន ត្រូវជូនព័ត៌មានបន្តទៅក្រុមប្រឹក្សាភិបាល ក្នុងរយៈពេលដ៏ឆាប់បំផុត ។

**មាត្រា ២៦.-**

រដ្ឋមន្ត្រីក្រសួងសុខាភិបាលអាចចាត់ឱ្យធ្វើអធិការកិច្ចឬការត្រួតពិនិត្យការងាររបស់វិទ្យាស្ថាន ក្នុងករណីដែលយល់ ថា ជាការចាំបាច់ស្របតាមល័ក្ខខ័ណ្ឌ និងបែបបទដែលមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិដែលមានជាធរមាន ។

## ផ្នែកទី ២

## អាណាព្យាបាល ហិរញ្ញវត្ថុ

**មាត្រា ២៧.-**

២៧.១-ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីការប្រជុំក្រុមប្រឹក្សាភិបាលនាយកនៃ **វ.ជ.ស.ស.** ត្រូវផ្ញើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ រដ្ឋមន្ត្រីក្រសួងសុខាភិបាលមានរយៈពេល ០១ (មួយ)ខែ គិតចាប់ពីថ្ងៃទទួលឯកសារដើម្បីផ្តល់យោបល់ ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានពេល ០២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលឯកសារដែលបញ្ជូនមកដោយនាយកនៃ **វ.ជ.ស.ស.** ដើម្បីផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៧.២-លិខិតយល់ព្រមដែលចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអ្នកតំណាង ត្រូវផ្ញើទៅនាយកនៃ**វ.ជ.ស.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល។ នាយកនៃ **វ.ជ.ស.ស.** ត្រូវជូនព័ត៌មាននេះ ដល់ក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មិនបានឆ្លើយតបក្នុងរយៈពេល ដូចមានកំណត់ខាងលើ របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ត្រូវចាត់ទុកថា បានទទួលការឯកភាព ។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានយោបល់ជំទាស់លើរបាយការណ៍ ដែលមានក្រុមប្រឹក្សាភិបាល ត្រូវកោះប្រជុំក្រុមប្រឹក្សាភិបាលឱ្យបានឆាប់រហ័សបំផុត ដើម្បីរិះរកមធ្យោបាយដោះស្រាយការជំទាស់ទាំងនេះ។

របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មិនអាចត្រូវសម្រេចយល់ព្រមបានឡើយ ក្នុងករណីដែលការជំទាស់ ដែលលើកឡើង ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពុំត្រូវបានដោះស្រាយនៅឡើយនោះ ។

**មាត្រា ២៨.-**

សេចក្តីសម្រេចដូចរៀបរាប់ខាងក្រោមនេះ របស់ក្រុមប្រឹក្សាភិបាល ឬនាយកនៃ **ទ.ជ.ស.ស.** ត្រូវដាក់ការអនុញ្ញាតជាមុនពី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល តាមការផ្តល់យោបល់ពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុរួមមាន ÷

- សេចក្តីសម្រេចស្តីពីការលក់ ឬផ្ទេរសិទ្ធិអចលនទ្រព្យ
- សេចក្តីសម្រេចស្តីពីការលើកលែងឥណទេយ្យ ដែលមានទឹកប្រាក់លើសពីការកំណត់ របស់ប្រកាសរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សេចក្តីសម្រេចស្តីពីកិច្ចព្រមព្រៀងខ្ចីប្រាក់ និងកិច្ចព្រមព្រៀងសម្រាប់ការធានាឬលិខិតស្រដៀងគ្នានេះ ។

**មាត្រា ២៩.-**

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវតែងតាំងមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ០១ (មួយ)រូប ប្រចាំ **ទ.ជ.ស.ស.** ។ មន្ត្រីនេះ មានភារកិច្ចធ្វើការត្រួតពិនិត្យជាមុន និងក្រោយលើ **ទ.ជ.ស.ស.** ស្របតាមអនុក្រឹត្យលេខ ៨១ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុ លើការចំណាយថវិការដ្ឋ នៅតាមក្រសួង ខេត្ត-ក្រុង-ក្រុងស្វយ័ត-រាជធានីភ្នំពេញ និងអង្គការសាធារណៈរដ្ឋបាល ។

មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុដែលមានចែងក្នុងអនុក្រឹត្យនេះ ត្រូវចូលរួមប្រជុំក្នុងសម័យប្រជុំ របស់ក្រុមប្រឹក្សាភិបាលតែគ្មានសិទ្ធិ បោះឆ្នោតទេ ។

**មាត្រា ៣០.-**

៣០.១-ការគ្រប់គ្រងរបស់អាណាប័កដើមខ្សែនៃ **ទ.ជ.ស.ស.** ស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

៣០.២-ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យ របស់ភ្នាក់ងារគណនេយ្យកណ្តាល នៃរតនាគារជាតិ និងក្រោមការត្រួតពិនិត្យ របស់អគ្គាធិការដ្ឋានហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣០.៣-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់ចែងធ្វើការផ្ទៀងផ្ទាត់ អធិការកិច្ច ឬ ការត្រួតពិនិត្យលើវិទ្យាស្ថានជាតិសុខភាពសាធារណៈនៅពេលដែលយល់ថាចាំបាច់ ស្របតាមល័ក្ខខ័ណ្ឌដែលមានចែង ក្នុងច្បាប់ពាក់ព័ន្ធ និងបទប្បញ្ញត្តិ ដែលមានជាធរមាន ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ៣១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធមានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។/.

រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣២
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

## ជំពូកទី ៣
## ផ្នែកទី ១
## អាណាព្យាបាលបច្ចេកទេស

**មាត្រា ២៣.-**

២៣.១-ក្នុងរយៈពេល ១៥ (ដប់ប្រាំ)ថ្ងៃ ក្រោយពីការប្រជុំក្រុមប្រឹក្សាភិបាលនៃ **ទ.ជ.ស.ស.** ត្រូវផ្ញើជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវកម្មវិធីអភិវឌ្ឍ និង គម្រោងថវិកាប្រចាំឆ្នាំ ដើម្បីសុំការយល់ព្រម ។ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មានរយៈពេល ០១ (មួយ)ខែ ចាប់ពីថ្ងៃ ដែលបានទទួលឯកសារសម្រាប់រៀបចំយោបល់របស់ខ្លួនជូនរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។ រដ្ឋមន្ត្រីអាណាព្យាបាលបច្ចេកទេសមាន០២ (ពីរ)ខែ គិតចាប់ពីថ្ងៃដែលបានទទួលឯកសារ ដែលបានបញ្ជូនដោយ **ទ.ជ.ស.ស.** ដើម្បីសម្រេចផ្តល់ការយល់ព្រមលើឯកសារទាំងនេះ ។

២៣.២-លិខិតយល់ព្រមត្រូវចុះហត្ថលេខាត្រឹមត្រូវ ដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល ឬ តំណាង ហើយត្រូវបានផ្ញើជូនទៅនាយកនៃ **ទ.ជ.ស.ស.** ដោយមានចម្លងជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ នាយកនៃ **ទ.ជ.ស.ស.** ត្រូវបញ្ជូនព័ត៌មាន នេះទៅឱ្យក្រុមប្រឹក្សាភិបាលយ៉ាងឆាប់បំផុត។

ក្នុងករណីដែលរដ្ឋមន្ត្រីក្រសួងសុខាភិបាល មិនបានឆ្លើយតបក្នុងរយៈពេលកំណត់ទេនោះ កម្មវិធីអភិវឌ្ឍ ឬ គម្រោងថវិកាប្រចាំឆ្នាំត្រូវចាត់ទុកថា បានទទួលការឯកភាព។

ប្រសិនបើរដ្ឋមន្ត្រីក្រសួងសុខាភិបាល ធ្វើការជំទាស់លើកម្មវិធីអភិវឌ្ឍ ឬ គម្រោងថវិកានេះ ប្រធាន ក្រុមប្រឹក្សាភិបាល ត្រូវរៀបចំការប្រជុំក្រុមប្រឹក្សាភិបាលជាបន្ទាន់ ដើម្បីពិភាក្សា និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយការជំទាស់ទាំងនេះ។

កម្មវិធីអភិវឌ្ឍនៃ **ទ.ជ.ស.ស.** និងថវិកាចំណាយជាមូលធនមិនអាចឱ្យអនុវត្តបានឡើយ ក្នុងករណីដែលការជំទាស់លើកឡើង ដោយប្រធានស្ថាប័នឬអាណាព្យាបាលបច្ចេកទេស។

ថវិកាចំណាយជាប្រចាំ អាចដាក់ឱ្យអនុវត្តត្រឹមលំនាំប្រព័ន្ធបំបែកជា ១២ (ដប់ពីរ) ប៉ុណ្ណោះនៅពេលដែលមាន ការជំទាស់ពីប្រធានស្ថាប័ន ឬ អាណាព្យាបាលបច្ចេកទេស ។

**មាត្រា ២៤.-**

២៤.១-រដ្ឋមន្ត្រីក្រសួងសុខាភិបាល អាចមានយោបល់ជំទាស់លើឯកសារដែលបានត្រូវបញ្ជូនមកខ្លួន ដូចមានចែងក្នុងមាត្រា២៣ខាងលើ មាន : កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ។ រដ្ឋមន្ត្រីក្រសួងសុខាភិបាល មានរយៈពេល ០១ (មួយ)ខែ សម្រាប់លើកឡើងនូវការជំទាស់ទាំងអស់នេះ ។

២៤.២-នាយកនៃ **ទ.ជ.ស.ស.** ត្រូវជូនព័ត៌មានទៅដល់ក្រុមប្រឹក្សាភិបាល នូវខ្លឹមសារនៃការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។ ក្រុមប្រឹក្សាភិបាលត្រូវធ្វើការពិភាក្សាឱ្យបានឆាប់បំផុត លើការជំទាស់របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងរិះរកមធ្យោបាយសម្រាប់ដោះស្រាយ ការជំទាស់ទាំងនេះ។ ប្រសិនបើក្រុមប្រឹក្សាភិបាល សម្រេចព្យួរ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦១០ អនក្រ.តត

## អនុក្រឹត្យ

## ស្ដីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យ លេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## សម្រេច

**មាត្រា ១:** តែងតាំងលោក ឈុន វណ្ណៈ ជាទីប្រឹក្សាក្រសួងបរិស្ថាន មានឋានៈស្មើ ប្រធានាយកដ្ឋាន ។

**មាត្រា ២:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែល ពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៦១១ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សម្រេច

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជន ចំនួន ០៧រូប ដែលបានចូលរួមក្នុងការកសាងសមិទ្ធផលនានា នៅក្នុងវត្តមុនីរង្សី ស្ថិតក្នុងឃុំប្រឡាយ ស្រុកស្ទោង ខេត្តកំពង់ធំ ដូចមានរាយឈ្មោះខាងក្រោម :-

១-លោក **ឈឹម គៃលាង** អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ច កិច្ចការវិនិយោគ និងទំនាក់ទំនងអន្តរជាតិ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ បានចំណាយអស់ ថវិកាចំនួន ១៤៤.៥០០ ដុល្លារ

២-លោក **ឆាំ សុជាតិវង្ស** និង លោកស្រី **អ៊ុន សុវណ្ណរិន្ទ** អភិបាលរងរាជធានីភ្នំពេញ បានចំណាយអស់ ថវិកាចំនួន ៥៥.០០០ ដុល្លារ

៣-លោក **ឈឹម គៃឡុង** និង លោកស្រី **ជឹម ហុងឡាង** ប្រធានក្រុមហ៊ុនសំណង់ F.C.K.L បានចំណាយអស់ ថវិកា ចំនួន ២១.៥០០ ដុល្លារ

៤-លោក **អាំង គី** និង លោកស្រី **ណៃ ជី** អភិបាលស្រុកស្ទោង ថវិកា ចំនួន ១៥.២០០ ដុល្លារ

៥-លោក **ឈឹម គៃលី** និង លោកស្រី **វណ្ណា ចំនួជានី** សប្បុរសជន នៅទីក្រុងភ្នំពេញ បានចំណាយអស់ថវិកា ចំនួន ១៣.៣០០ ដុល្លារ

៦-លោក **ឆេង យូ** និងលោកស្រី **គង់ គីមលី** សប្បុរសជននៅខេត្តកំពង់ធំ ថវិកា ចំនួន ១៥.១០០ ដុល្លារ

៧-លោក **លឹម ម៉ុនហេង** និង លោកស្រី **គី ឆេងឡុច** ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយ-កម្ម និងសំណង់ និងភូមិបាលស្រុកស្ទោង បានចំណាយអស់ ថវិកា ចំនួន ១៥.១០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៦១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **ធិបឌិន្ទ** ជាកិច្ចបច្ឆាមរណៈ ប្រគេនចំពោះព្រះសពព្រះតេជគុណ **អាន ង៉យ** អតីតព្រះមេគណខេត្តកំពង់ធំ ដែលកាលពីព្រះអង្គនៅមានព្រះជន្ម មានស្នាព្រះហស្ត និងគុណបំណាច់ធំៗជាច្រើន ក្នុងការដឹកនាំអប់រំព្រះសង្ឃទូទាំងខេត្ត ព្រមទាំងបានបរិច្ចាគបច្ច័យចូលរួម កសាងសមិទ្ធផលនានា ចំនួន ៣៦០.២៤៥ ដុល្លារអាមេរិក ។

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៦១៣...អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពី ការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន ១៧រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ចូលរួមជួយកសាងព្រះវិហារវត្តគរ ព្រះវិហារវត្តព្រះពន្លាជ័យ ផ្លូវក្រាលកៅស៊ូ ផ្លូវក្រាលគ្រួសក្រហម និងដាក់ប្រព័ន្ធលូរំដោះទឹក នៅក្នុងឃុំរតនៈ ឃុំវត្តគរ ស្រុកបាត់ដំបង និង នៅក្នុងឃុំរូងជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

**ក_មេដាយមាសស្ថាបនាជាតិ :**

១-លោក **កែវ លីម** និង លោកយាយ **រស់ យឿន** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចំណាយអស់ថវិកា ចំនួន ៦៧.៧៣៩ ដុល្លារ ។

២-លោក **អ៊ុក សេង** និង លោកស្រី **ស៊ឿ រ៉ាំ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចំណាយអស់ថវិកា ចំនួន ២១.៧៦៧ ដុល្លារ ។

៣-លោក **ឆិត វីរា** តំណាងសប្បុរសជនក្នុង និងក្រៅប្រទេស ថវិកាចំនួន ៧៨.៥៣៤.៥០០ រៀល

៤-លោក **ក្រាញ់ គីម** និង លោកយាយ **ម្លូន ចាំ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចំណាយអស់ថវិកា ចំនួន ១០.២០០ ដុល្លារ ។

៥-ព្រះតេជគុណ **ហឿង តាំងហ៊ាន** ចៅអធិការវត្តព្រះពន្លាជ័យ បច្ច័យ ចំនួន ១០.៣០០ ដុល្លារ

៦-លោក **ពេជ្រ វណ្ណា** សប្បុរសជននៅខេត្តបាត់ដំបង ថវិកា ចំនួន ១៧.៣៩២ ដុល្លារ

**ខ_មេដាយប្រាក់ស្ថាបនាជាតិ :**

១-លោក **ក្រាញ់ សារឿន** និងលោកស្រី **វណ្ណៈ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចំណាយអស់ថវិកា ចំនួន ៦.៣៩០ ដុល្លារ

២-អ្នកឧកញ៉ាវិសេសវិជ្ជា សាស្ត្រាចារ្យ វេជ្ជបណ្ឌិត **ម៉ី សាម៉ីឌី** និងលោកជំទាវ **គីម ម៉ូរី** សប្បុរសជន នៅក្រុងភ្នំពេញ បានចំណាយអស់ថវិកា ចំនួន ៦.១៥៥ ដុល្លារ ។

៣-ឧបាសិកា **រស់ យោ** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.០០០ ដុល្លារ

៤-ឧបាសិកា **ហែម សៀង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៥.០០០ ដុល្លារ

**គ-មេដាយសំរឹទ្ធស្ថាបនាជាតិ :**

១-លោកយាយ **កៅ គីមឡុង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ៣.០០០ ដុល្លារ

២-លោក **ម៉ឿ ជាឈិម** និង លោកស្រី **សារ៉េត** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក បានចំណាយអស់ថវិកា ចំនួន ១.៩៦៧ ដុល្លារ

៣-លោក **សូ ហ៊ីង** និង លោកស្រី **ស៊ុយ សេង** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ចំនួន ១.២០០ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបាត់ដំបង ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ៦១៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អាជ្ញាធរអប្សរា"

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អាជ្ញាធរអប្សរា"

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៦៧ ចុះថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០០៤ ស្តីពីការកែសម្រួលមាត្រា៤ និងមាត្រា៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការកែសម្រួលបទប្បញ្ញត្តិមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរ ដើម្បីការពាររមណីយដ្ឋាន និងរៀបចំតំបន់អង្គរហៅថា "អាជ្ញាធរអប្សរា"

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ ២០០៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាននៃអាជ្ញាធរអប្សរា

-យោងតាមសំណើរបស់ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា

# សម្រេច

**មាត្រា១ :** ត្រូវបានតែងតាំងលោក **ហុក ម៉េងសែ** ឋានន្តរស័ក្តិវរមន្ត្រីថ្នាក់លេខ ៩ ជាប្រធាននាយកដ្ឋានរដ្ឋបាល បុគ្គលិក ហិរញ្ញកិច្ច និងទំនាក់ទំនងសាធារណៈ នៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា ។

**មាត្រា២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានអាជ្ញាធរអប្សរា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៣
-រាជកិច្ច
-ឯកសារ កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៦១២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពីការជូនមេដាយស្ថាបនាជាតិ

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា

**សម្រេច**

**មាត្រា១ :** ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេនព្រះសង្ឃ និងជូនសប្បុរសជន ចំនួន០៦រូប ដែលបានចូលរួមជួយកសាងសមិទ្ធផលនានា លើវិស័យព្រះពុទ្ធសាសនា និង សង្គមជាតិ ដូចជា កុដិ សាលាឆាន់ សាលាធម្មសភា ខឿនព្រះវិហារ និងសមិទ្ធផលជាច្រើនទៀត នៅក្នុងពុទ្ធសីមា *វត្តឥន្រ្ទើយ៍សរៈ* ហៅ *វត្តកំពង់ធំ* ស្រុកស្ទឹងសែន និង វត្តមួយចំនួនទៀតនៅក្នុងខេត្តកំពង់ធំ ដូចមានរាយព្រះនាម និងនាមខាងក្រោម :-

**ក-មេដាយមាសស្ថាបនាជាតិ :**

១-ព្រះតេជគុណ **ហាយ សូហ៊ីម** បានបរិច្ចាគអស់បច្ច័យ ចំនួន ១៤.០២៧ ដុល្លារ
២-ព្រះតេជគុណ **ស៊ិន សោភ័ណ្ឌ** បានបរិច្ចាគអស់បច្ច័យ ចំនួន ១៣.១៩៦ ដុល្លារ
៣-ព្រះតេជគុណ **ខែ ម៉ៅ** បានបរិច្ចាគអស់បច្ច័យ ចំនួន ១២.៣២៤ ដុល្លារ
៤-ព្រះតេជគុណ **សៀង សុខ** បានបរិច្ចាគអស់បច្ច័យ ចំនួន ១១.៥៧៣ ដុល្លារ

**ខ-មេដាយប្រាក់ស្ថាបនាជាតិ :**

១-ឧបាសក **ម៉ិត ណេត** បានបរិច្ចាគអស់ថវិកា ចំនួន ៨.១០៣ ដុល្លារ
២-ឧបាសក **ឌី សេង** បានបរិច្ចាគអស់ថវិកា ចំនួន ៧.០១២ ដុល្លារ

**មាត្រា២:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា និង អភិបាលខេត្តកំពង់ធំ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៦១៦ អនក្រ.តត

## អនុក្រឹត្យ
## ស្តីពីការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខណ្ឌមន្ត្រី នគរបាលជាតិកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៦/២៧៤ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ២០០៦ ស្តីពីការកែសំរួលព្រះរាជក្រឹត្យលេខ នស/រកត/០៩៩៥ /៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានឃើញអនុក្រឹត្យលេខ ៧១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- យោងតាមសំណើរបស់ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន

## សម្រេច

**មាត្រា ១ :** ត្រូវបានតែងតាំងលោកវរៈសេនីយ៍ឯក **គាន ទ្រី** ជាជំនួយការឯកឧត្តមអនុប្រធានអចិន្ត្រៃយ៍អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈ**ស្មើប្រធាននាយកដ្ឋាន** ។

**មាត្រា ២ :** បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៣ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ប្រធានអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទល័យឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា៣
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៦១៧ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការទទួលស្គាល់គណៈកម្មាធិការកណ្តាល អាណត្តិទី ៤ សមាជិកបំរុង ឥស្សរជន និងអគ្គលេខាធិការ អគ្គលេខាធិការរងកាកបាទក្រហមកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ ៣៧៨/នស ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ១៩៥៨ ស្តីពីការទទួលស្គាល់សមាគមជាតិកាកបាទក្រហមកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០២/១១២ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការប្រើប្រាស់ និងការការពារបដិរូបកាកបាទក្រហម និងអឌ្ឍចន្ទក្រហម
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/០៥០២/១១៣ ចុះថ្ងៃទី ០៦ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការទទួលស្គាល់កាកបាទក្រហមកម្ពុជា
- បានឃើញកំណត់ហេតុ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០០៦ របស់អង្គមហាសន្និបាតកាកបាទក្រហមកម្ពុជា លើកទី ៤ នាថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីការជ្រើសរើសសមាសភាពគណៈកម្មាធិការកណ្តាលថ្មីអាណត្តិទី ៤
- យោងតាមសំណើរបស់ប្រធានកាកបាទក្រហមកម្ពុជា

## សម្រេច

**មាត្រា ១ :** ទទួលស្គាល់គណៈកម្មាធិការកណ្តាល អាណត្តិទី ៤ សមាជិកបំរុក ឥស្សរជន និងអគ្គលេខាធិការដ្ឋាន កាកបាទក្រហមកម្ពុជា ដូចមានសមាសភាពខាងក្រោម :

១. គណៈកម្មាធិការកណ្តាល :

| | | |
|---|---|---|
| ១-សម្តេចព្រះមហាក្សត្រី | នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ | ព្រះប្រធានកិត្តិយស |
| ២-លោកជំទាវ | ប៊ុន រ៉ានី ហ៊ុន សែន | ប្រធាន |
| ៣-ឯកឧត្តម | អ៊ុក ដាមរី | អនុប្រធានទី ១ |
| ៤-លោកជំទាវ | អាន្នី សុខ អាន | អនុប្រធានទី ២ |
| ៥-លោកជំទាវ | អ៊ុក ម៉ាលី | អគ្គហេរញ្ញិក |
| ៦-សម្តេចចៅហ្វាវាំង | គង់ សំអុល | សមាជិក |
| ៧-ឯកឧត្តមសាស្ត្រាចារ្យ | មី សាមីឌី | សមាជិក |
| ៨-ឯកឧត្តម | ញឹម វណ្ណដា | សមាជិក |
| ៩-លោកជំទាវ | ឃួន សុដារី | សមាជិកា |
| ១០-លោកជំទាវ | ញ៉ែម សុផានី ងួន ញិល | សមាជិកា |
| ១១-ឯកឧត្តម | ហេង តៃគ្រី | សមាជិក |
| ១២-ឯកឧត្តម | ពិត ចំណាន | សមាជិក |
| ១៣-ឯកឧត្តម | ឈុន ស៊ីរុន | សមាជិក |
| ១៤-ឯកឧត្តម | ប៉ា សុជាតិវង្ស | សមាជិក |
| ១៥-ឧកញ៉ា | គិត ម៉េង | សមាជិក |
| ១៦-លោកជំទាវ | ជឹង សុភាព | សមាជិកា |
| ១៧-ឯកឧត្តម | លី យ៉ុងផាត់ | សមាជិក |
| ១៨-ឯកឧត្តម | ម៉ុង ឫទ្ធី | សមាជិក |
| ១៩-ឯកឧត្តម | កុក អាន | សមាជិក |
| ២០-លោកជំទាវ | ម៉ែន ភក្តី ហុក ឡុងឌី | សមាជិកា |
| ២១-លោកជំទាវ ឧកញ៉ា | លីម ឈីវហួរ | សមាជិកា |
| ២២-ឯកឧត្តម | អ៊ឹង ប៊ុនហ៊ួរ | សមាជិក |
| ២៣-ឯកឧត្តម | ទ្រី មេង | សមាជិក |
| ២៤-ឯកឧត្តម | គីម គុណវឌ្ឍន៍ | សមាជិក ។ |

២-សមាជិកបំរុង :

| | |
|---|---|
| ១-លោក | បាន ឆន |
| ២-លោកជំទាវ | សន ម៉ារ៉ាដា |
| ៣-ឯកឧត្តម | ជុំ កុសល |

៣-ឥស្សរជន :

១-លោកជំទាវ តៅ ឌៀន ឡៅ ចាញ់

២-លោកជំទាវ សុខ កែវ ច័ន្ទ សារុន

៣-លោកជំទាវ ជា ខេង ស៊ុយ សែម

៤-អគ្គលេខាធិការដ្ឋាន :

១-លោកជំទាវ ពុំ ចន្ទីនី អគ្គលេខាធិការ

២-លោកស្រី ម៉ែន នារីសោភ័គ អគ្គលេខាធិការរង ។

**មាត្រា ២ :** គណៈកម្មាធិការកណ្តាលកាកបាទក្រហមកម្ពុជា ដែលបានជ្រើសរើសតាមការបោះឆ្នោត របស់មហាសន្និបាតទូទាំងប្រទេស នាថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០៦ ត្រូវបំពេញភារកិច្ចទៅតាមអំណាច ដែលមានចែងក្នុងមាត្រា ១៥ នៃលក្ខន្តិកៈរបស់កាកបាទក្រហមកម្ពុជា ។

**មាត្រា ៣ :** អគ្គលេខាធិការដែលជ្រើសតាំងដោយគណៈកម្មាធិការកណ្តាលត្រូវបំពេញភារកិច្ចទៅតាមមុខនាទី ដែលមានចែងក្នុងមាត្រា ២១ នៃលក្ខន្តិកៈរបស់កាកបាទក្រហមកម្ពុជា ។

**មាត្រា ៤ :** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៥ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានកាកបាទក្រហមកម្ពុជា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ អភិបាលខេត្ត ក្រុង និងបណ្តាសមាសភាពដែលមានរាយព្រះនាម នាម ដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គណៈសង្ឃនាយក នៃព្រះរាជាណាចក្រកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៥
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦១៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការផ្ទេរភារកិច្ច និងតែងតាំងមុខតំណែង
## នាយនគរបាលជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស /រកម /០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## សំរេច

**មាត្រា ១ .-** ត្រូវបានផ្ទេរភារកិច្ច និងតែងតាំងមុខតំណែងលោកឧត្តមសេនីយ៍ត្រី **ខាំ ចន្ថា** អត្តលេខ ០២៦០ ពីអនុប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទៅជាប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុងក្រសួងមហាផ្ទៃ ។

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុក ទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦*

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

*កន្លែងទទួល*
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ១៧៧០ MOC / SM 2006

# ប្រកាស

## ស្តីពីវិធានការចាំបាច់មួយចំនួនសំរាប់គ្រប់គ្រងការនាំចេញ ក្រោមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ,
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ,
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម ,
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងពាណិជ្ជកម្ម ,
- យោងតាមការចាំបាច់របស់ក្រសួង ។

## សំរេច

**ប្រការ ១ :** រាល់អ្នកនាំចេញទំនិញក្រោមប្រព័ន្ធ MFN និង GSP ចាំបាច់ត្រូវមកបំពេញបែបបទស្នើសុំវិញ្ញាបនប័ត្របញ្ជាក់ប្រភពដើមទំនិញ (C/O) និង បំពេញកាតព្វកិច្ចបង់កំរៃគ្រប់គ្រងការនាំចេញ EMF (Export Management Fee) ក្នុងរយៈពេល ៣០ ថ្ងៃបន្ទាប់ពីទំនិញត្រូវបាននាំចេញរួចហើយ ។

**ប្រការ ២ :** កាលបរិច្ឆេទត្រួតពិនិត្យទំនិញរបស់មន្ត្រីគយ និង កាំកុងត្រូលដែលបានបញ្ជាក់នៅលើកំណត់ហេតុរួមស្តីពីការត្រួតពិនិត្យទំនិញ នឹងត្រូវបានកំណត់យកជាកាលបរិច្ឆេទនៃការចេញទំនិញ ។

**ប្រការ ៣ :** អ្នកនាំចេញទំនិញសំលៀកបំពាក់ក្នុងឈុតជាមួយគ្នាដែលស្ថិតក្នុងប្រភេទពីរផ្សេងគ្នា (Two Different Categories) ត្រូវបំពេញកាតព្វកិច្ចបង់ EMF ពាក់កណ្តាលថ្លៃក្នុងប្រភេទ (Category) នីមួយៗ ។

**ប្រការ ៤ :** ក្នុងករណីមិនយកចិត្តទុកដាក់ យឺតយូរក្នុងការស្នើសុំ C/O និងបង់ EMF លើសពីកាលបរិច្ឆេទកំណត់ក្នុងប្រការ ១ អ្នកនាំចេញត្រូវទទួលរងពិន័យ ១% ( មួយភាគរយ) ក្នុងមួយថ្ងៃលើតំលៃ EMF ដែលត្រូវបង់ ។

**ប្រការ ៥ :** អ្នកនាំចេញត្រូវទទួលធ្វើអធិការកិច្ចផលិតកម្មមួយខែមួយលើកគត់ ដើម្បីផ្ទៀងផ្ទាត់បទដ្ឋាន និង កាត់ស្តុកការចំណាយវត្ថុធាតុដើមតាម C/O នីមួយៗដែលក្រសួងបានចេញជូន ដោយមិនអនុញ្ញាតអោយការងារផ្ទៀងផ្ទាត់បទដ្ឋាន និងកាត់ស្តុកនេះនៅជំពាក់ឆ្លងខែដែលនាំដល់ការច្របូកច្របល់ក្នុងការគ្រប់គ្រងសន្និធិ និងការអនុវត្តន៍វិធានប្រភពដើមរបស់ប្រទេសដែលផ្តល់ភាពអនុគ្រោះពាណិជ្ជកម្មចំពោះកម្ពុជា ។

**ប្រការ ៦ :** ការអនុវត្តន៍កិច្ចសន្យាជួលផលិតត្រូវបានអនុញ្ញាតជូនអ្នកនាំចេញទាំងអស់ ដោយជួលអ្នកទទួលផលិតដែលមានច្បាប់អនុញ្ញាតត្រឹមត្រូវ និង គោរពច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ។ រាល់លើកដែលធ្វើកិច្ចសន្យាជួលផលិត ត្រូវជូនដំណឹងមកនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្មទៅតាមគំរូណែនាំដែលបានកំណត់ ។

**ប្រការ ៧ :** ករណីអ្នកនាំចេញមិនយកចិត្តទុកដាក់បំពេញកាតព្វកិច្ចក្នុងប្រការ ៥ និង ប្រការ ៦ ខាងលើ ក្រសួងពាណិជ្ជកម្មនឹងផ្អាកការផ្តល់ C/O ជូនរហូតដល់ការខ្វះខាតដែលកើតមានក្នុងប្រការទាំង ២ ត្រូវបានបំពេញគ្រប់ជ្រុងជ្រោយ ។

**ប្រការ ៨ :** សេចក្តីប្រកាស និង លិខិតជូនដំណឹងទាំងឡាយដែលមានខ្លឹមសារផ្ទុយពីនេះ នឹងត្រូវទុកជានិរាករណ៍ ។

**ប្រការ ៩ :** នាយិកាខុទ្ទកាល័យ អគ្គនាយកបច្ចេកទេស អគ្គនាយករដ្ឋបាលហិរញ្ញវត្ថុ អគ្គាធិការ ប្រធាននាយកដ្ឋានកាំកុងត្រូល ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ប្រធាននាយកដ្ឋានអាស៊ាន និង អង្គការអន្តរជាតិ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធាននាយកដ្ឋានគណនេយ្យ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះអោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃទី ០១ ខែ តុលា ឆ្នាំ ២០០៦ តទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ កញ្ញា ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

<u>**ចម្លងជូន :**</u>

- ខុទ្ទកាល័យ **សម្តេចនាយករដ្ឋមន្ត្រី**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ស ខេង**
- ខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល
- ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា
- ទីចាត់ការគយ និង រដ្ឋាករ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- រោងចក្រកាត់ដេរសំលៀកបំពាក់នៅកម្ពុជា " ដើម្បីសហការអនុវត្តន៍ "
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៧៧៧៧ ពណ.នគក

ភ្នំពេញថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៦

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **រាជធីតា គ្រុប អ៊ីន**

**(អ ធី ឌី)**

**REACHTHIDA GROUP INC.**

**(RTD)**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8827/06P ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី **គុល សុខុម**

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៧ A ផ្លូវលេខ២៣០ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ

-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ

-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង

-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ

-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ

-បើកសាលារៀន

-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម

-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម

-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស

-សេវាផ្សាយពាណិជ្ជកម្ម

-បោះពុម្ពផ្សាយ

-ផលិតខ្សែភាពយន្ត វីដេអូ CD

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ជ. ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ប្រតិភូរដ្ឋមន្ត្រីទទួលបន្ទុក
រដ្ឋលេខាធិការ

គឹម ស៊ីថន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៧២៨ ពណ.នគក

ភ្នំពេញថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **អាន់លីមីធីត អិកសេស**

**UNLIMITED XCESS Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3005/06E ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : សហគ្រាសឯកបុគ្គលទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី MARIA CARMINA LAINI SAMSON SERAPIO

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ០២៧ ផ្លូវលេខ ៣៧១ ភូមិត្នោតជ្រុំ សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម :
-ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការដូសដុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ

-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ

-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់

-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត

-វិនិយោគលើវិស័យកសិកម្ម : ដាំដុះណាំ ចិញ្ចឹមសត្វ

-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ចិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
ប្រធានគណៈរដ្ឋលេខាធិការ

ចាម ប្រសិទ្ធ

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងព័ត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៧៧៩ ពណ.នគក

ភ្នំពេញថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០០៦

# ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

**សូមបញ្ជាក់ថា :**

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ប្រាផាត់សន**

**PRAPATSORN Co., Ltd.**

អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 8864/06P ចុះថ្ងៃទី ០៤ ខែ កក្កដា ឆ្នាំ ២០០៦

មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោក RUNGROJ HEMANSUTIKUN ប្រធានក្រុមប្រឹក្សាភិបាល
លោក **គាត រស្មី** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ២០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ១១Eo. ផ្លូវលេខ ៥៥៦ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងនូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ទិញ លក់ ជួល បញ្ចាំមូលនីធិពាណិជ្ជកម្ម-ទិញ លក់ ជួល ដីធ្លី ផ្ទះសំបែង
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស ស្តុកឃ្លាំង និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន

- សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម ។

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រង ខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម
រដ្ឋលេខាធិការ
ឱក_ប៊ុន

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
- អគ្គនាយកដ្ឋានរាជកិច្ច និង សេវាកុំព្យូទ័រ
- សាលាក្រុងភ្នំពេញ
- មន្ទីរពាណិជ្ជកម្មរាជធានី ភ្នំពេញ "មុខការ"
- ឯកសារ -កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
លេខ ១៧៣០ ពណ.នតក

ភ្នំពេញថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០០៦

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សូមបញ្ជាក់ថា :

ក្រុមហ៊ុនពាណិជ្ជកម្មឯកជនមួយ ត្រូវបានចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម និងទទួលស្គាល់ជានីតិបុគ្គលពេញលក្ខណៈច្បាប់ គិតចាប់ពីកាលបរិច្ឆេទនៃការចុះបញ្ជីនេះតទៅ តាមលក្ខខ័ណ្ឌដូចខាងក្រោម :

១- នាមករណ៍របស់ក្រុមហ៊ុន : **ហាយ អូវ ខេមបូ**
HAI AU CAMBO Co.,Ltd.
អត្តលេខចុះបញ្ជីពាណិជ្ជកម្ម : Co. 3013/06E ចុះថ្ងៃទី ០៥ ខែ កក្កដា ឆ្នាំ ២០០៦
មានទ្រង់ទ្រាយជា : ក្រុមហ៊ុនឯកជនទទួលខុសត្រូវមានកំរិត

២- អភិបាលក្រុមហ៊ុន : លោកស្រី LY KIM DU ប្រធានក្រុមប្រឹក្សាភិបាល
លោក **ហួត សោភ័ណ្ឌ** អភិបាល

៣- ដើមទុនក្រុមហ៊ុន : ចំនួន ៥០.០០០.០០០ រៀល

៤- ទីស្នាក់ការក្រុមហ៊ុន : ផ្ទះលេខ ៣៥ C ផ្លូវលេខ ២៣១ សង្កាត់ផ្សារដើមគរ ខណ្ឌទួលគោក រាជធានីភ្នំពេញ

៥- កម្មវត្ថុអាជីវកម្ម : -ពាណិជ្ជកម្ម : ទិញ លក់ ផ្លាស់ប្តូរទំនិញ នីហរ័ណ អាហរ័ណទំនិញគ្រប់ប្រភេទ នាំចូលឱសថ សំភារៈបរិក្ខារពេទ្យគ្រប់ប្រភេទ
-ការជួលដាក់ឃ្លាំងទូវផលិតផល ទំនិញគ្រប់ប្រភេទ -ការជួសជុលសំភារៈ ទំនិញគ្រប់ប្រភេទ
-ប្តូរប្រាក់ ផលិត ទិញ លក់ គ្រឿងអលង្ការ
-មន្ទីរពេទ្យពិគ្រោះព្យាបាលជំងឺ
-បើកសាលារៀន
-សេវាយកកំរៃជើងសារ -ភ្នាក់ងារពាណិជ្ជកម្ម -តំណាងពាណិជ្ជកម្ម
-សេវាពិគ្រោះយោបល់លើផ្នែកហិរញ្ញវត្ថុ ពាណិជ្ជកម្ម
-សេវារកការងារជូនអតិថិជនធ្វើក្នុងនិងក្រៅប្រទេស
-សេវាផ្សាយពាណិជ្ជកម្ម
-បោះពុម្ពផ្សាយ
-ផលិតខ្សែភាពយន្ត វីដេអូ CD
-ដឹកជញ្ជូន : ផ្លូវទឹក ផ្លូវគោក ផ្លូវអាកាស -សេវាបញ្ជូន និងចែកចាយទំនិញ
-សេវាយកកំរៃជើងសារលើការដឹកជញ្ជូន
-សាងសង់ ជួសជុល អាគារ ស្ពាន ថ្នល់
-ទេសចរណ៍ : សណ្ឋាគារ ភោជនីយដ្ឋាន មជ្ឈមណ្ឌលកំសាន្ត
-វិនិយោគលើវិស័យកសិកម្ម : ដាំដំណាំ ចិញ្ចឹមសត្វ
-វិនិយោគលើវិស័យឧស្សាហកម្ម : រោងចក្រ សិប្បកម្ម

៦- ថិរវេលា : ៩៩ ឆ្នាំ

ដើម្បីធ្វើប្រតិបត្តិការលើមុខជំនាញនីមួយៗ ក្រុមហ៊ុនត្រូវសុំការអនុញ្ញាតជាមុនពីក្រសួង ឬ ស្ថាប័ន ដែលគ្រប់គ្រងមុខជំនាញទាំងនោះ និងសុំការអនុញ្ញាតបើកទីតាំងទីស្នាក់ការរបស់ក្រុមហ៊ុន ពីអាជ្ញាធរដែនដី ។

អ្នកទទួលខុសត្រូវនៃក្រុមហ៊ុន ត្រូវអនុវត្តសមស្របទៅតាមច្បាប់ជាធរមាន ។/

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

រដ្ឋលេខាធិការ

ឱ្សក_ម៉ុង

**ចំលងជូន**

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួង ការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- ក្រសួងទេសចរណ៍
- ក្រសួងពត៌មាន
- ធនាគារជាតិនៃកម្ពុជា
- ក្រសួងអប់រំយុវជន និងកីឡា
- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ
- ក្រសួងសាធារណការ និងដឹកជញ្ជូន
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
